តុលា - ធ្នូ ២០១៥ | លេខ ០២

CAMBODIA RICE FEDERATION

# ព្រឹត្តិបត្រព័ត៌មាន

## រួមគ្នាលើកស្ទួយអង្ករកម្ពុជា



ចេញផ្សាយដោយ

**សហពន្ធ័ស្រូវអង្ករកម្ពុជា**

អាស័យដ្ឋាន៖ អគារពាណិជ្ជកម្មសូម៉ា ជាន់ទី ៧
អាគារលេខ ២C ផ្លូវលេខ ១២០ សង្កាត់ ផ្សារថ្មី ||
ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
គេហទំព័រ៖ www.crf.org.kh
សារអេឡិចត្រូនិក៖ info@crf.org.kh
ទូរស័ព្ទ៖ +៨៥៥ (0) ២៣ ៥៥៩ ៨៩៩៩
+៨៥៥ (0) ៨៧ ៥៥៩ ៨៩៩

និពន្ធ និងចងក្រងដោយ

ក្រុមការងារលេខាធិការដ្ឋានសហពន្ធ័ស្រូវអង្ករកម្ពុជា

ចូលរួមឧបត្ថម្ភដោយ

- Nikoline Investment Co., LTD
- ANZ ROYAL
- i_TRADING
- Buhler



# មាតិកា


- អារម្ភកថា
- សង្ខេបព្រឹត្តិការណ៍សំខាន់ៗរបស់ ស.អ.ក
- បទយកការណ៍ស្តីពី *"បញ្ហាប្រឈមរបស់សហគមន៍កសិករ"*
- ព័ត៌មានអំពីគម្រោងអភិវឌ្ឍន៍សំខាន់ៗក្នុងវិស័យកសិកម្ម និងកិច្ចសន្យាកសិកម្ម

*- ស្វែងយល់អំពីកម្មវិធីពានរង្វាន់ស្រែ ប.វ.ស ល្អ របស់អង្គការសេដាក*
*- គម្រោងប្រព័ន្ធចីរភាពកសិចំណីអាហារអាស៊ាន (ASEAN-SAS) របស់ អង្គការ GIZ*
*- កម្មវិធី កម្ពុជាហាវេស របស់ USAID ជួយសហគមន៍បង្កើនការផ្គត់ផ្គង់បរិមាណគ្រាប់ពូជស្រូវគុណភាពល្អ*
*- ស្វែងយល់អំពីប្រព័ន្ធធានារ៉ាប់រងកសិកម្មខ្នាតតូចកម្ពុជា*
*- បទពិសោធន៍ក្នុងការធ្វើកិច្ចសន្យាផលិតកម្មកសិកម្ម (Contract Farming) ផលិត និងផ្គត់ផ្គង់ស្រូវសរីរាង្គរវាងសហគមន៍កសិកម្មចំនួន ៨ និងក្រុមហ៊ុនអេមរុ រ៉ាយស៍ (ខេមបូឌា) ដែលគាំទ្រដោយគម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា*

- ព័ត៌មានអំពីវឌ្ឍនភាពនៃការអភិវឌ្ឍន៍ម៉ាកឃីហោអង្ករកម្ពុជា *"ការរៀបចំម៉ាកអង្កររួម និងការជម្រុញផ្សព្វផ្សាយម៉ាកអង្ករកម្ពុជា"*
- ព័ត៌មានអំពីស្ថានភាពតម្រូវការ និងផែនការអភិវឌ្ឍន៍ពូជស្រូវកម្ពុជា *"ស្ថានភាពនៃវិស័យពូជស្រូវ"*
- បញ្ជីឈ្មោះក្រុមហ៊ុនអ្នកនាំចេញ និងរោងម៉ាស៊ីនកិនស្រូវដែលបានចុះហត្ថលេខាលើក្រមសីលធម៌ (ស.អ.ក)
- ព័ត៌មានអំពីបច្ចុប្បន្នភាព និងបញ្ហាប្រឈមសំខាន់នៃរោងម៉ាស៊ីនកិនស្រូវនៅកម្ពុជា *"រោងម៉ាស៊ីនកិនស្រូវ៖ បញ្ហាប្រឈមសំខាន់ៗចំនួន ៧តម្រូវឲ្យមានដំណោះស្រាយជាបន្ទាន់"*
- សម្រង់អត្ថបទព័ត៌មានសំខាន់ៗដែលបានចុះផ្សាយនៅក្នុងសារព័ត៌មានក្នុងស្រុកពី ខែតុលា ដល់ ខែធ្នូ ឆ្នាំ ២០១៥
- ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ

# អាវម្ភកថា



*ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា*

ការបង្កើនការប្រកួតប្រជែងរបស់ស្រូវអង្ករកម្ពុជា គឺជាកត្តាចំបងក្នុងការជម្រុញនិរន្តរភាពនៃការផលិត ផ្គត់ផ្គង់ ការកែច្នៃ និងការនាំចេញរបស់អង្ករកម្ពុជា។ ដើម្បីសម្រេចគោលដៅនេះ មានកិច្ចការជាច្រើនដែលត្រូវធ្វើ ដោយមានការសហការជាមួយភាគីរដ្ឋ ភាគីឯកជន និងដៃគូអភិវឌ្ឍន៍នានា ក្នុងការរួមគ្នាដោះស្រាយបញ្ហាប្រឈម នានានៅក្នុងវិស័យស្រូវអង្កររបស់យើង ក្នុងរយៈពេលខ្លី មធ្យម និងវែង។

ក្នុងការលើកស្ទួយវិស័យស្រូវអង្ករ សហព័ន្ធស្រូវអង្ករកម្ពុជា បានកំណត់គោលដៅអាទិភាពចំនួន៣  រួមមាន ពូជ ឃ្លាំង និងការទទួលឥណទាននិងទីផ្សារ។ ជាមួយអាទិភាពទាំងបីនេះ យើងសង្ឃឹមថា នឹងជួយពង្រឹងគ្រឹះនៃវិស័យស្រូវអង្ករឲ្យកាន់តែរឹងមាំក្នុងចង្វាក់ផលិតកម្ម និងកែច្នៃទាំងមូល ចាប់តាំងពីកសិករ រោងម៉ាស៊ីន អ្នកនាំចេញ រហូតដល់អ្នកប្រើប្រាស់។ ជាមួយនឹងផែនការ៥ឆ្នាំ ដែលយើងនឹងដាក់ចេញនៅពេលខាងមុខ យើងនឹងផ្តោតទៅលើគោលដៅនិងផែនការសកម្មភាព ក្នុងការជួយដល់វិស័យស្រូវអង្ករ ពិសេសទាក់ទងនឹងដំណោះស្រាយទាក់ទង នឹងផ្នែកអាទិភាពទាំងបីខាងលើ។

នៅថ្ងៃទី២៤-២៦ ខែមករា ឆ្នាំ២០១៦ខាងមុខ សហព័ន្ធនឹងប្រារព្ធនូវវេទិកាស្រូវអង្ករកម្ពុជាលើកទី៥ នៅរាជធានីភ្នំពេញ។ ក្នុងវេទិកានេះ គឺជាឱកាសដ៏មានសារៈសំខាន់ សម្រាប់សមាជិកសមាជិកា និងអ្នកចូលរួម ទាំងអស់បានស្វែងយល់អំពីផែនការ៥ឆ្នាំ របស់សហព័ន្ធស្រូវអង្ករកម្ពុជា និងផ្លាស់ប្តូរយោបល់គ្នាដើម្បីស្វែងរកដំណោះស្រាយសម្រាប់បញ្ហាប្រឈមនានា ពិសេសរួមចំណែកជាធាតុចូលក្នុងផែនការ៥ឆ្នាំរបស់សហព័ន្ធ។ យើងបានអញ្ជើញវាគ្មិន មកពីបណ្តាក្រសួង និងក្រុមហ៊ុនពាក់ព័ន្ធ អ្នកជំនាញជាតិនិងអន្តរជាតិ ដើម្បីធ្វើបទបង្ហាញ អំពីគំនិតថ្មីៗ ដែលបានអនុវត្តនៅតាមបណ្តាប្រទេសនានា។

ខ្ញុំបាទជឿជាក់ថា សមាជិកសមាជិកា និងភាគីពាក់ព័ន្ធទាំងអស់ នឹងចូលរួមផ្លាស់ប្តូរព័ត៌មាន មតិយោបល់  និង បទពិសោធន៍សម្រាប់ចូលរួមដោះស្រាយបញ្ហាប្រឈមនានា ដើម្បីលើកស្ទួយវិស័យស្រូវអង្ករកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥
ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា

**សុខ ពុទ្ធិវុធ**

## សង្ខេបព្រឹត្តិការណ៍សំខាន់ៗរបស់ ស.អ.ក

## សមាជិករោងម៉ាស៊ីនកិនស្រូវរីករាយក្រោយ ទទួលបានលិខិតអញ្ជើញចូលរួមវេទិកាស្រូវអង្ករលើកទី ៥



សមាជិករោងម៉ាស៊ីនកិនស្រូវក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងសៀមរាប បានសម្តែងក្តីរីករាយ ក្រោយទទួលបានលិខិតអញ្ជើញឲ្យចូលរួមនៅក្នុងវេទិកាស្រូវអង្ករលើកទី ៥ នៅថ្ងៃទី ២៤ ដល់ ២៦ ខែមករា ឆ្នាំ ២០១៦ខាងមុខ ពីក្រុមការងារបុគ្គលិកសហព័ន្ធស្រូវអង្ករកម្ពុជា។

គួររំលឹកជូនថា កាលពីថ្ងៃទី ២២ ដល់ ២៦ ខែធ្នូ ឆ្នាំ ២០១៥ កន្លងទៅនេះ ក្រុមការងារបុគ្គលិកសហព័ន្ធស្រូវអង្ករកម្ពុជា បានចុះជួបជាមួយរោងម៉ាស៊ីនកិនស្រូវ ដែលជាសមាជិករបស់ ស.អ.ក ដើម្បីសំណេះសំណាល និងអញ្ជើញសមាជិករោងម៉ាស៊ីនកិនស្រូវចូលរួមវេទិកាស្រូវអង្ករលើកទី៥។

នៅក្នុងអំឡុងពេលជួបសំណេះសំណាល សមាជិករោងម៉ាស៊ីនក៏បានលើកឡើងអំពីផលលំបាកមួយចំនួន ដែលរោងម៉ាស៊ីនរបស់ពួកគាត់កំពុងជួបប្រទះ ដូចជា ថ្លៃភ្លើងអគ្គីសនីថ្លៃ ថ្លៃបង់ពន្ធដារ និងបញ្ហាទីផ្សារអង្ករក្នុងស្រុក ដែលរំខានដោយវត្តមានអង្ករវៀតណាមជាដើម។ សមាជិករោងម៉ាស៊ីន ក៏សំណូមពរដល់ ស.អ.ក និងរាជរដ្ឋាភិបាលធ្វើយ៉ាងណាជួយដោះស្រាយបញ្ហាជូនពួកគាត់ ដើម្បីពួកគាត់អាចបន្តប្រកបរបររោងម៉ាស៊ីនកិនស្រូវនេះទៀតបាន ដោយពួកគាត់បញ្ជាក់ថា មានរោងម៉ាស៊ីនមួយចំនួនធំ បានបន្តបិទទ្វារជាបណ្តើរៗហើយ៕



## កិច្ចប្រជុំជាមួយសមាជិករោងម៉ាស៊ីនកិនស្រូវ នៅក្នុងខេត្តបាត់ដំបង

នៅរសៀលថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១៥ សមាជិកក្រុមប្រឹក្សាភិបាល សហព័ន្ធស្រូវអង្ករកម្ពុជា ដឹកនាំដោយប្រធានសហព័ន្ធលោក **សុខ ពុទ្ធិវុធ** បានចូលរួមនៅក្នុងចិ្កប្រជុំមួយជាមួយសមាជិករោងម៉ាស៊ីនកិនស្រូវមកពីខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងសៀមរាប នៅក្នុងរោងម៉ាស៊ីនច្រាយ សុន ខេត្តបាត់ដំបង។

គោលបំណងសំខាន់នៃកិច្ចប្រជុំគឺដើម្បីសំណេះសំណាល និងអញ្ជើញសមាជិករោងម៉ាស៊ីនកិនស្រូវចូលរួមវេទិកាស្រូវអង្ករលើកទី៥។ សមាជិកសរុបប្រមាន ៥០នាក់បានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំនេះ៕









## ជំនួបប្រជុំរវាង ស.អ.ក និង អគ្គនាយកដ្ឋានកសិកម្ម

នារសៀលថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៥នេះ ប្រធាន ស.អ.ក លោក **សុខ ពុទ្ធិវុធ** បានដឹកនាំកិច្ចប្រជុំជាមួយ ឯកឧត្តមបណ្ឌិត **ហ៊ាន វណ្ណហាន** អគ្គនាយករងនៃអគ្គនាយកដ្ឋានកសិកម្ម និងជាប្រធានលេខាធិការដ្ឋានច្រកចេញចូលតែមួយ នៅឯអគ្គនាយកដ្ឋានកសិកម្ម ដែលតំណាង ស.អ.ក មានចំនួន ៥រូប រួមមាន៖ អនុប្រធាន ស.អ.ក លោកឧកញ៉ា **គឹម សាវុធ** និងលោកឧកញ៉ា **ហ៊ុន ឡាក់** សមាជិក ស.អ.ក ដែលជាអ្នកនាំចេញ លោក **យ៉ន សុវណ្ណ** និងអគ្គលេខាធិការ ស.អ.ក លោក **មូល សារិទ្ធិ**។

ក្នុងជំនួបរយៈពេល ២ម៉ោងជាង ជាមួយ ឯកឧត្តមបណ្ឌិត **ហ៊ាន វណ្ណហាន** គឺទទួលបានលទ្ធផលផ្លែផ្កាដូចជា៖
- ភាគីទាំងពីរបានឯកភាពថានឹងសហការគ្នាដើម្បីជួយសម្រួលក្នុងការចុះឈ្មោះជូនសមាជិកសហព័ន្ធ ដែលជាអ្នកនាំអង្ករចូលទៅប្រទេសចិនឲ្យមានភាពលឿន និងតម្លាភាព។
- បានឯកភាពគ្នាឲ្យមានក្រុមការងាររបស់សហ័ន្ធស្រូវអង្ករកម្ពុជានឹងចូលរួមជាមួយក្រុមការងារអគ្គនាយកដ្ឋានកសិកម្ម ដើម្បីធ្វើការងារនេះ។
- ដោយយោងលើ ឯកសារដែលទទួលបានពីខាងភាគីចិនមានភាពយឺតពេក ដូចនេះ ខាងអគ្គនាយកដ្ឋានកសិកម្ម នឹងស្នើសុំទៅភាគីចិនដើម្បីសុំពន្យាពេលឬ បញ្ជូនឯកសារទៅជាតំណាក់ៗ ទោះជាយ៉ាងក៏ដោយខាងអគ្គនាយកដ្ឋានកសិកម្ម នឹងខិតខំចុះវាយតម្លៃដល់ក្រុមហ៊ុនដែលបាន និងកំពុងនាំចូលប្រទេសចិន ជាអាទិភាពសិន ព្រោះដើម្បីកុំឲ្យមានការរាំងស្ទះដំណើរការនាំចេញ។ បន្ទាប់មកនឹងធ្វើការជាមួយក្រុមហ៊ុនបន្តបន្ទាប់ទៀត។
- កិច្ចសហការផ្សេងៗទៀតនាពេលខាងមុខ៕





## កិច្ចប្រជុំជាមួយសមាជិករោងម៉ាស៊ីនកិនស្រូវ ក្នុងខេត្តព្រៃវែង កំពង់ចាម និងត្បូងឃ្មុំ

នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី០៣ ខែធ្នូ ឆ្នាំ២០១៥ ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា លោក **សុខ ពុទ្ធិវុធ** រួមជាមួយក្រុមការងារបុគ្គលិកលេខាធិការដ្ឋានសហព័ន្ធ បានចុះជួបប្រជុំ និងសំណេះសំណាលជាមួយសមាជិករោងម៉ាស៊ីនកិនស្រូវក្នុងខេត្តព្រៃវែង កំពង់ចាម និងត្បូងឃ្មុំ នៅសាលប្រជុំសភាពាណិជ្ជកម្មខេត្តព្រៃវែង។

តំណាងសមាជិករោងម៉ាស៊ីនខេត្តព្រៃវែង កំពង់ចាម និងត្បូងឃ្មុំ ចំនួន ១១នាក់ បានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំនេះ។

គោលបំណងសំខាន់ៗ នៃកិច្ចប្រជុំនេះរួមមាន៖
(១) ពិភាក្សាអំពី Quota អង្ករស និងស្នើសុំផ្តល់តួលេខបរិមាណអង្ករដែលអាចផ្គត់ផ្គង់បាន(មានបង្ហាញ Spec)
(២) កិច្ចសហប្រតិបត្តការលើគម្រោងវិយោគឃ្លាំង និងម៉ាស៊ីនសម្ងួត (Ware receipt and Dryer)
(៣) អញ្ជើញសមាជិកចូលរួមវេទិកាស្រូវអង្ករលើកទី៥
(៤) ទស្សនកិច្ចទៅកាន់រោងម៉ាស៊ីនកិនស្រូវ មួយចំនួនរបស់សមាជិក
(៥) បន្តធ្វើបច្ចុប្បន្នភាព Members′ Profile
(៦) ចែកជូនន្ទូវព្រឹត្តិបត្រព័ត៌មានសហព័ន្ធ និងបន្តផលិតអត្ថបទព័ត៌មានសម្រាប់ចុះផ្សាយ
(៧) ផ្សេងៗ៕










## ប្រធាន ស.អ.ក បានដឹកនាំទស្សនកិច្ចសិក្សា ទៅកាន់មជ្ឈមណ្ឌលផលិតពូជស្រូវ របស់ក្រុមហ៊ុន អិល ប៊ី អិន ( LBN Group )

នៅព្រឹកថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥ ប្រធានសហពន្ធ័ស្រូវអង្ករកម្ពុជា លោក **សុខ ពុទ្ធិវុធ** បានដឹកនាំដំណើរទស្សនកិច្ចសិក្សាទៅមជ្ឈមណ្ឌលផលិតពូជស្រូវរបស់ក្រុមហ៊ុន អិលប៊ិអិន (LBN Group) នៅស្រុកស្ទោង ខេត្តកំពង់ធំ ដោយបានការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់ លោកឧញ៉ា **លីម ប៊ុណា** ដែលជាប្រធាន LBN group។ អ្នកចូលរួមប្រមាណជាជិត ៣០នាក់ រួមមាន លោកឧកញ៉ា **គឹម សាវុធ** អនុប្រធាន ស.អ.ក លោកឧកញ៉ា **វង្ស ម៉ិនហេង** ប្រធាន



GMP Exco សមាជិកស.អ.ក និងបុគ្គលិកលេខាធិការដ្ឋាន។ សូមបញ្ជាក់ថាមជ្ឈមណ្ឌលនេះកំពុងដំណើរការផលិតពូជស្រូវដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារអង្ករកម្ពុជា ជាពិសេសឆ្លើយតបទៅនឹងគោលនយោបាយនាំចេញរបស់រាជរដ្ឋាភិបាល៕





## ប្រធានស.អ.ក ធ្វើបទបង្ហាញស្តីអំពីអនាគតវិស័យស្រូវអង្ករកម្ពុជា នៅក្នុងសន្និសិទ "អង្ករពិភពលោកលើក ទី ៧"

នៅព្រឹកថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០១៥នេះ ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា លោក សុខ ពុទ្ធិវុធ បានធ្វើបទបង្ហាញស្តីអំពីអនាគតវិស័យស្រូវអង្ករកម្ពុជា នៅក្នុងសន្និសិទ "អង្ករពិភពលោកលើក ទី ៧" នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ុ ចាប់ពីថ្ងៃទី ២៨ ដល់ ៣០ ខែតុលា ឆ្នាំ ២០១៥នេះ៕







## សមាជិក ស.អ.ក ចំនួន ២២ក្រុមហ៊ុន ចូលរួមក្នុងសន្និសិទ "អង្ករពិភពលោកលើកទី ៧"

សមាជិក ស.អ.ក ដែលជាតំណាងក្រុមហ៊ុនរោងម៉ាស៊ីនកិនស្រូវ នាំចេញ ក្រុមហ៊ុនដឹកជញ្ជូន និងក្រុមហ៊ុនពិនិត្យគុណភាព (Inspection) ចំនួន ២២ក្រុមហ៊ុន រួមទាំងក្រុមការងារសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានចូលរួមក្នុងសន្និសិទ "អង្ករពិភពលោកលើក ទី ៧" នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ុ ចាប់ពីថ្ងៃទី ២៨ ដល់ ៣០ ខែតុលា ឆ្នាំ ២០១៥នេះ៕



## អនុប្រធាន ស.អ.ក ផ្ដល់បទសម្ភាសន៍ដល់ទូរទស្សន៍ជាតិវៀតណាម អំពីស្ថានភាពវិស័យស្រូវអង្ករកម្ពុជា






តាមការស្នើសុំពីសំណាក់ទូរទស្សន៍ជាតិវៀតណាម ដោយសូមសម្ភាស៍អំពីស្ថានភាពវិស័យស្រូវអង្ករកម្ពុជា ពោលគឺបទពិសោធន៍ក្នុងដំណើរការរៀបចំម៉ាកអង្ករ និងការនាំចេញអង្កររបស់កម្ពុជា ដើម្បីដាក់ផ្សព្វផ្សាយក្នុងកម្មវិធីទូរទស្សន៍ជាតិមួយនេះ នៅព្រឹកថ្ងៃទី ៨ ខែតុលានេះ អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា លោកឧកញ៉ា **ហ៊ុន ឡាក់** បានផ្ដល់បទសម្ភាស៍ដល់ទូរទស្សន៍ជាតិវៀតណាម ដោយបានចែករំលែកពីស្ថានភាពជាក់ស្ដែង អំពីការនាំចេញអង្ករ ដំណើរការរៀបចំម៉ាកអង្កររបស់កម្ពុជា និងការរៀបចំយន្តការ (វិន័យ និងក្រមសីលធម៌) ដែលសហព័ន្ធបានកំពុងនឹងអនុវត្ត៕

---

## ការចុះទៅជួបសហគមន៍ស្ទឹងជីនិត និង មជ្ឈមណ្ឌលផលិតពូជស្រូវរបស់ក្រុមហ៊ុន អិលប៊ីអិន

( LBN Group )

នៅថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០១៥នេះ បុគ្គលិកលេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា ៣រូប បានចុះទៅទស្សនកិច្ច និងជួបប្រជុំជាមួយតំណាងសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត ដែលមានការជួយសម្របសម្រួលដោយ លោក **សេង សុភ័គ** នាយកមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ (ISC) ទីតាំងនៅស្រុកសន្ទុក ខេត្តកំពង់ធំ។ សមាសភាពអ្នកចូលរួមទាំងអស់ប្រមាណជា ២០នាក់ ដែលមាន តំណាងមកពីក្រសួងកសិកម្ម (MAFF/SNEC) តំណាង (ISC) និង តំណាងសហគមន៍កសិករចំនួន ៥ (សហគមន៍ស្ទឹងជីនិត សហគមន៍តាំងក្រសាំង សហគមន៍ត្នោតជុំ សហគមន៍បឹងលៀស និងសហគមន៍អង្គគោ)។ គោលបំណងសំខាន់នៃទស្សនកិច្ចគឺ ពិនិត្យការងារគ្រប់គ្រងគុណភាពស្រូវ ពិសេសជួយសម្របសម្រួលទីផ្សារស្រូវរបស់សហគមន៍កសិករនេះ ដោយ ស.អ.ក នឹងបញ្ជូនព័ត៌មានទៅរោងម៉ាស៊ីនស្រូវនានាដែលជាសមាជិករបស់ខ្លួន។

គួរបញ្ជាក់ផងដែរថា សហគមន៍នេះគម្រោងលក់ស្រូវរួមគ្នា (ស្រូវផ្ការំដួល) ប្រមាណជា ៥០០តោន ដែលនឹងចាប់ផ្តើមប្រមូលផល និងលក់នៅខែវិច្ឆិកា ឆ្នាំ២០១៥នេះ។



ក្នុងអំឡុងពេលជួបប្រជុំ បុគ្គលិក ស.អ.ក លោក **ផង់ ផល្លា** បានបង្ហាញពីស្ថានភាពតម្រូវការទីផ្សារអង្ករជាតិក៏ដូចជាអន្តរជាតិ តម្រូវការពូជស្រូវ និងបច្ចេកទេសដាំដុះ។ លោក **យ៉ាន ពេជ្រ** បុគ្គលិក ស.អ.ក ម្នាក់ទៀតក៏បាន ទាញចំណាប់អារម្មណ៍សហគមន៍ឲ្យផ្តោតទៅលើតម្រូវការរបស់រោងម៉ាស៊ីនស្រូវ បច្ចេកទេសទុកដាក់ស្រូវ និងការវាស់សំណើមស្រូវ។ល។

នៅថ្ងៃដដែលនេះ បុគ្គលិកលេខាធិការដ្ឋាន ក៏បានទៅមជ្ឈមណ្ឌលពូជស្រូវរបស់ក្រុមហ៊ុន អិលប៊ិអិន (LBN) នៅស្រុកស្ទោង ខេត្តកំពុងធំ ដែលមណ្ឌលនេះកំពុងដំណើរការផលិតពូជស្រូវ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារអង្ករកម្ពុជា ជាពិសេសឆ្លើយតបទៅនឹងគោលនយោបាយនាំចេញរបស់រាជរដ្ឋាភិបាល៕







## ប្រធាន ស.អ.ក បានចូលរួមចែករំលែក បទពិសោធន៍របស់កម្ពុជានៅក្នុងកិច្ចប្រជុំ ស្តីពី "ការអភិវឌ្ឍវិស័យស្រូវអង្ករសម្រាប់កាត់បន្ថយភាពក្រីក្រ"

នៅថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០១៥ ប្រធាន ស.អ.ក លោក **សុខ ពុទ្ធិវុធ** បានចូលរួមនៅក្នុងសិក្ខាសាលាមួយស្តីពីការចែករំលែកបទពិសោធន៍លើការអភិវឌ្ឍវិស័យស្រូវអង្ករសម្រាប់ការកាត់បន្ថយភាពក្រីក្រនៅក្រសួងកសិកម្ម និងព្រៃឈើ ប្រទេសឡាវ (PDR)។ អ្នកចូលរួមមាន៖ មន្ត្រីមកពីក្រសួងកសិកម្មនៃប្រទេសឡាវ មន្ត្រីមកពីក្រសួងពាក់ព័ន្ធ និងតំណាងមកពីដៃគូអភិវឌ្ឍន៍បានចូលរួម។ ក្នុងអំឡុងសិក្ខាសាលានេះ លោក **សុខ ពុទ្ធិវុធ** បានចែករំលែកដល់អ្នកចូលរួមទាំងអស់ ពីបទពិសោធន៍របស់កម្ពុជានូវអ្វីដែលកម្ពុជាបានធ្វើ និងអ្វីដែលកម្ពុជាកំពុងធ្វើហើយគ្រោងនឹងធ្វើក្នុងពេលអនាគតដើម្បីអភិវឌ្ឍវិស័យស្រូវអង្ករនេះ។ នៅក្នុងសិក្ខាសាលានេះមានការផ្លាស់ប្តូរបទពិសោធន៍យ៉ាងសកម្មនៃព័ត៌មាន និងទស្សនៈក្នុងចំណោមអ្នកចូលរួម។ ហើយមន្ត្រីឡាវអាចនឹងរៀបចំតារាងពេលវេលាមួយ ដើម្បីធ្វើទស្សនកិច្ចនៅកម្ពុជានាពេលអនាគតដល់ខ្លីនេះ៕



## កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ស.អ.ក លើកទី៩

នារសៀលថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៥ ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា លោក **សុខ ពុទ្ធិវុធ** បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៩ ដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាល តំណាងសមាជិកក្រុមប្រឹក្សាភិបាល និងបុគ្គលិក ស.អ.ក ប្រមាណជា ១៧ រូប នៅឯការិយាល័យលេខាធិការដ្ឋាន។ របៀបវារៈសំខាន់ៗរួមមាន៖ (១)ពិភាក្សា អំពី កូតាការនាំចេញទៅប្រទេសចិន និងប្រទេសឥណ្ឌូនេស៊ី។ (២) ពិភាក្សា អំពី ដំណើរការនៃក្រុមការងារទី៩ តំណាងវិស័យឯកជន ផ្នែកស្រូវអង្ករ។ (៣) ផ្សេងៗ៕



## សមាជិកមួយចំនួនរបស់ ស.អ.ក ចូលនៅក្នុងការធ្វើបទបង្ហាញស្តីអំពី បច្ចេកវិទ្យាថ្មី និងចុងក្រោយបង្អស់លំដាប់ពិភពលោក ក្នុងការទុកដាក់ និងដឹកជញ្ជូនទំនិញរាយ

នៅរសៀលថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០១៥នេះ សមាជិកមួយចំនួនរបស់ ស.អ.ក និងបុគ្គលិកលេខាធិការដ្ឋាន ស.អ.ក ដឹកនាំដោយ ឧកញ៉ា **ហ៊ុន ឡាក់** អនុប្រធាន ស.អ.ក បានចូលនៅក្នុងការធ្វើបទបង្ហាញស្តីអំពី បច្ចេកវិទ្យាថ្មី និងចុងក្រោយបង្អស់លំដាប់ពិភពលោក ក្នុងការទុកដាក់ និងដឹកជញ្ជូនទំនិញរាយ ដែលរៀបចំដោយ កំពង់ផែស្វយ័តភ្នំពេញ ក្រោយអធិបតីភាព ឯកឧត្តម **ហ៊ី បាវី**។



បច្ចេកវិទ្យាថ្មីនេះ គឺជាបច្ចេទវិទ្យារបស់ប្រទេសអាល្លឺម៉ង់ ហើយដែលត្រូវបានអះអាងថា មានប្រសិទ្ធិភាពខ្ពស់ និងចំណេញច្រើនក្នុងការទុកដាក់ និងដឹកជញ្ជូនទំនិញរាយ ដោយអាចរៀបចំទុកដាក់ទំនិញផ្សេងៗ ពិសេសគឺកសិផលបញ្ចូលក្នុងកុងតឺន័រចំណុះ ២៥តោនត្រឹមរយៈពេល ២៥នាទី និងដែលអាចកាត់បន្ថយជំហ៊ានផ្សេងៗក្នុងការដឹកជញ្ជូន រហូតអាចនាំចេញផ្ទាល់បាន។



អនុប្រធាន ស.អ.ក ឧកញ៉ា **ហ៊ុន ឡាក់** មានប្រសាសន៍ថា ជារួមបច្ចេកវិទ្យាមួយនេះគឺល្អ ប៉ុន្តែវាហាក់មិនទាន់អាចអនុវត្តបានចំពោះទំនិញអង្ករ។ មូលហេតុដោយសារតែ តម្រូវការពីអ្នកទិញខ្លះ ក្នុងការវេចខ្ចប់ក្នុង ចំណុះផ្សេងៗគ្នា ដូចជា ៥គីឡូក្រាម ២គីឡូក្រាម ជាដើម។ ប៉ុន្តែ ឧកញ៉ា **ហ៊ុន ឡាក់** បន្តថាវាអាចត្រូវជាមួយនឹងទំនិញមួយចំនួនទៀតដូចជា ដំឡូងមី ពោត សណ្តែក ជំរាកឈើ និងទំទិញរាយផ្សេងៗទៀត៕



## អ្នកសារព័ត៌ជាច្រើន បានចូលរួមនៅក្នុង សន្និសីទសារព័ត៌មាន ស្តីពី "វេទិកាស្រូវអង្ករកម្ពុជាលើកទី ៥"

អ្នកសារព័ត៌ចំនួន ២៣នាក់ តំណាងមកពីស្ថាប័នសារព័ត៌មានជាតិ និងអន្តរជាតិ រួមមានកាសែត ទូរទស្សន៍ វិទ្យុទស្សនាវដ្តី និងសារព័ត៌មាន Online បានអញ្ជើញចូលរួមនៅក្នុងសន្និសីទសារព័ត៌មាន ស្តីពី "វេទិកាស្រូវអង្ករកម្ពុជាលើកទី ៥" របស់សហព័ន្ធស្រូវអង្ករកម្ពុជា (ស.អ.ក) សហការជាមួយសម្ព័ន្ធសមាគមសហគ្រាសធុនតូចនិងមធ្យមកម្ពុជា (FASMEC) នៅព្រឹកថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៥នេះ។



ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា លោក **សុខ ពុទ្ធីវុធ** អនុប្រធាន ឧកញ៉ា **គឹម សាវុធ** និងប្រធានសម្ព័ន្ធសមាគមសហគ្រាសធនតូច និងមធ្យមកម្ពុជា ឧកញ៉ា **តែ តាំងប៉** និង លោកស្រី **ថេរ សុខា** ប្រធានគណៈកម្មាធិការប្រត្តិបត្តិជម្រុញផ្សព្វផ្សាយទីផ្សារអន្តរជាតិ បានចូលរួមជាវាគ្មិន និងឆ្លើយតបទៅនឹងសំណួររបស់អ្នកសារព័ត៌មាន។ អ្នកសារព័ត៌មានបានសួរសំណួរជាច្រើនទាក់ទងនឹងទីផ្សារស្រូវអង្ករកម្ពុជា តម្លៃស្រូវ និងអង្ករ បញ្ហាផលិតកម្ម និងផលប៉ះពាល់នៃគ្រោះរាំងស្ងួត លំហូរស្រូវអង្ករជាមួយប្រទេសជិតខាង និងកិច្ចខិតខំប្រឹងប្រែងរបស់សហព័ន្ធស្រូវអង្ករកម្ពុជាសម្រាប់អនាគតរបស់វិស័យស្រូវអង្ករកម្ពុជាផងដែរ។




សូមបញ្ជាក់ថា "វេទិកាស្រូវអង្ករកម្ពុជាលើកទី ៥" ដែលគម្រោងនឹងរៀបចំ នៅថ្ងៃទី ២៤-២៥-២៦ ខែមករា ឆ្នាំ ២០១៦ នៅសណ្ឋាគារសុខាភ្នំពេញ នឹងប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា៕

## បុគ្គលិក ស.អ.ក ចូលរួមសិក្ខាសាលាថ្នាក់តំបន់ ស្តីពី "ការគាំទ្រវិស័យស្រូវអង្ករ សម្រាប់កាត់បន្ថយភាពក្រីក្រ នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ"

ចាប់ពី ១០-១២ ខែវិច្ឆិកា ឆ្នាំ២០១៥ លោក **ហ៊ីម ខទៀត** និង លោក **តុន ខេមរា** បុគ្គលិក ស.អ.ក ចូលរួមក្នុងសិក្ខាសាលា ថ្នាក់តំបន់ ចំនួន ៣ ថ្ងៃ ស្តីពី "ការគាំទ្រវិស័យស្រូវអង្ករ សម្រាប់ កាត់បន្ថយភាពក្រីក្រ នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ" នៅឯសណ្ឋាគារ Peninsula ទីក្រុងបាងកក ប្រទេសថៃ។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងដោយ ធនាគារពិភពលោក (World Bank Group)។

គោលបំណង នៃសិក្ខាសាលា នេះគឺដើម្បី ចែករំលែកចំណេះដឹងឆ្លងប្រទេស ដើម្បីឲ្យវិស័យស្រូវអង្ករកាន់តែរីកចម្រើនសម្រាប់ការកាត់បន្ថយភាពក្រីក្រថ្នាក់មហាអនុតំបន់ទន្លេមេគង្គ។ មានអ្នកចូលរួម ប្រមាណជា ៤៥ នាក់ ដែលជាអ្នកជំនាញក្នុងវិស័យស្រូវអង្ករមន្ត្រីរាជរដ្ឋាភិបាល កំពុងធ្វើការលើយុទ្ធសាស្ត្រ និងផែនការសកម្មភាព ស្រូវអង្ករ ដែលមកពីប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងថៃ គូអភិវឌ្ឍន៍ បានចូលរួមក្នុងសិក្ខាសាលានេះ ដើម្បីចែករំលែកបទពិសោធន៍ និងចំណេះដឹង ទៅវិញទៅមក លើសង្វាក់តម្លៃអង្ករ ដែលមានឥទ្ធិពលលើវិស័យស្រូវអង្ករ ដើម្បីការបន្ថយភាពក្រីក្រ និង អាហាររូបត្ថម្ភ ក្នុងការឆ្លើយតបគោលនយោបាយដើម្បីឱ្យការងារលើវិស័យស្រូវអង្ករបានល្អប្រសើរឡើង៕





# បទយកការណ៍ស្តីពី
## ប្រធានសហគមន៍ស្ទឹងជីនិតៈ "បញ្ហាប្រឈមរបស់សហគមន៍កសិករនៅតែមាន"

"បញ្ហាប្រឈមរបស់សហគមន៍កសិករនៅតែមាន" នេះគឺជាសម្តីរបស់ប្រធានសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត អ្នកស្រី **រ៉ុម សារឿន**។ ឆ្លើយតបមកកាន់ក្រុមការងារ ស.អ.ក អ្នកស្រី **សារឿន** មានប្រសាសន៍ថាៈ "បញ្ហាប្រឈមចំបងៗ របស់សហគមន៍អ្នកស្រីនាពេលបច្ចុប្បន្នគឺ ពូជស្រូវមិនសុទ្ធពិបាកលក់ (គ្មានទីផ្សារ) និង ការជួសជុលថែទាំប្រព័ន្ធទឹក ដោយចំណាយច្រើន ប៉ុន្តែចំណូលតិច"។



សហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិតមានទីតាំងនៅភូមិឈើទាល ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលបានចាប់ផ្តើមរៀបចំជាសហគមន៍ឡើងនៅឆ្នាំ២០០២ និងបានចុះឈ្មោះនៅក្រសួងធនធានទឹក និងឧតុនិយមនៅឆ្នាំ២០០៦។ សហគមន៍នេះកំពុងដំណើរការគ្រប់គ្រង និងផ្តល់ទឹកឲ្យសមាជិកធ្វើស្រូវ ប្រមាណជា ២,៨៥៥ គ្រួសារ ហើយទំហំផ្ទៃដីស្រោចស្រពសរុបមាន ២,៦១៧.៦០ ហិកតា និងលទ្ធភាពអាងទឹកអាចស្តុកទឹកបាន ៣៩ លានម៉ែតគូប។ សកម្មភាពសំខាន់ៗដែលសហគមន៍កំពុងអនុវត្តរួមមានការជួសជុលថែទាំប្រព័ន្ធប្រលាយទឹកស្ទឹងជីនិត និងការលក់ស្រូវរួមគ្នា។

កាលពីឆ្នាំ២០១៤ សមាជិកសហគមន៍នេះប្រឈមខ្លាំងជាមួយការលក់ស្រូវមិនបានថ្លៃ ដោយសារការដាំដុះពូជមិនបានសុទ្ធល្អ ដែលតម្រូវការទីផ្សារគេត្រូវការស្រូវពូជសុទ្ធល្អ។ ប៉ុន្តែនៅឆ្នាំ ២០១៥នេះ អ្នកស្រី **សារឿន** ជឿជាក់ថា ការលក់ស្រូវរួមគ្នាលើកនេះនឹងបានតម្លៃថ្លៃប្រសើរជាងឆ្នាំកន្លងទៅ ពីព្រោះថាសហគមន៍បានជម្រើសពូជសុទ្ធដាំ ដោយបានរើសតែពូជសុទ្ធល្អតែប៉ុណ្ណោះ និងសង្ឃឹមថាបានទទួលទិន្នផលខ្ពស់ ៩០%។ ទោះជាយ៉ាងណាក្តី អ្នកស្រីបន្តថា បញ្ហាតម្លៃស្រូវនៅតែជាក្តីកង្វល់របស់កសិករពួកគាត់។

ចុងក្រោយអ្នកស្រី **សារឿន** មានសំណូមពរមកកាន់សហព័ន្ធស្រូវអង្ករកម្ពុជា សូមឲ្យសហព័ន្ធស្រូវអង្ករកម្ពុជា ជួយជម្រុញយ៉ាងណាឲ្យស្រូវរបស់សហគមន៍កសិករពួកគាត់លក់បានថ្លៃ និងជួយណែនាំនូវពូជស្រូវសុទ្ធល្អដែលត្រូវជាមួយនឹងតម្រូវការទីផ្សារដល់កសិករពួកគាត់ ដោយអ្នកស្រីបញ្ជាក់ថាការនេះនឹង ធ្វើឲ្យកសិករកាន់តែមានកម្លាំងចិត្ត និងព្យាយាមបង្កបង្កើតផលស្រូវ ដើម្បីលើកស្ទួយវិស័យស្រូវអង្ករកម្ពុជា៕





# ព័ត៌មានអំពីគម្រោងអភិវឌ្ឍន៍សំខាន់ៗក្នុងវិស័យកសិកម្ម និងកិច្ចសន្យាកសិកម្ម

## ស្វែងយល់អំពីកម្មវិធីពានរង្វាន់ស្រែ ប.វ.ស ល្អ របស់អង្គការសេដាក

ដើម្បីចូលរួមចំណែកលើកទឹកចិត្តដល់កសិករក្នុងការអនុវត្តនូវគោលការណ៍ប្រព័ន្ធប្រពលវប្បកម្មស្រូវ តាមគោលការណ៍ធម្មជាតិ (ប.វ.ស) អោយបានកាន់តែល្អប្រសើ និងបង្កើតជាគំរូភាពជោគជ័យ ក្នុងមុខរបរធ្វើស្រែ អង្គការសេដាក តែងតែរៀបចំឱ្យមានរង្វាន់លើកទឹកចិត្តដល់កសិករឆ្នើមៗប្រចាំឆ្នាំ។ សម្រាប់ឆ្នាំ២០១៤ នេះអង្គការសេដាក់ បានរៀបចំឱ្យមានពានរង្វាន់ សម្រាប់កសិករដែលធ្វើស្រែតាមបច្ចេកទេស ប.វ.ស ល្អជាងគេ ។

កសិករដែលធ្វើស្រែ ប.វ.ស បានល្អជាងគេ (ទទួលបានទិន្នផលខ្ពស់ និងទទួលបានប្រាក់ចំណូលច្រើនជាងគេ) និងទទួលបានរង្វាន់ដូចខាងក្រោមៈ

១. ចំណាត់ថ្នាក់លេខ ១ ទទួល បានមេគោចំនួន ៥ ក្បាល
២. ចំណាត់ថ្នាក់លេខ ២ ទទួល បានមេគោចំនួន ៤ ក្បាល
៣. ចំណាត់ថ្នាក់លេខ៣ ទទួល បានមេគោចំនួន ៣ ក្បាល
៤. ចំណាត់ថ្នាក់លេខ ៤ ទទួល បានមេគោចំនួន ២ ក្បាល
៥. ចំណាត់ថ្នាក់លេខ ៥ ទទួល បានមេគោចំនួន ១ ក្បាល



លក្ខខណ្ឌចូលរួមប្រកួតៈ ចំពោះអ្នកដែលចង់ចូលរួមប្រកួត ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោមនេះ៖

១. ផ្ទៃដីត្រូវស្មើ ឬធំជាង ២៥អារ
២. អនុវត្តតាមគោលការណ៍ និងបច្ចេកទេសប្រព័ន្ធប្រពលវប្បកម្ម (ប.វ.ស)
៣. មិនប្រើប្រាស់សារធាតុគីមីដូចជា ថ្នាំពុល ជីគីមី និងថ្នាំបំប៉នផ្សេងៗ
៤. ត្រូវធ្វើការកត់ត្រាឱ្យបានត្រឹមត្រូវ (នូវទិន្នន័យមួយចំនួនដូចជា ទំហំដី បរិមាណពូជ បរិមាណ ជីប្រើ ចន្លោះគុម្ពស្ទូង...។ល។)
៥.ដាក់ពាក្យសុំចូលរួមប្រកួតឲ្យបានមុនថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤
៦. បង់ប្រាក់ចូលរួមប្រកួតចំនួន ២០,០០០រៀលសម្រាប់បេក្ខជនម្នាក់

ចំណុចសំខាន់ៗ សម្រាប់ធ្វើការវិនិច្ឆ័យគឺៈ

១. ទិន្នផល
២. ទំហំផ្ទៃដី
៣. ប្រាក់ចំណូលទទួលបានពីដីស្រែ
៤. គុណភាពនៃការកត់ត្រាព័ត៌មាន(រូបថត, ព័ត៌មានបច្ចេកទេស, ទិន្នន័យផលិត/ដាំដុះ ការវិភាគចំណូលចំណាយ។
៥. ការផ្សព្វផ្សាយបន្តដល់កសិករផ្សេងទៀត

សម្រាប់ឆ្នាំ២០១៤នេះ កសិករដែលជាប់ចំណាត់ថ្នាក់លេខ១ បានទៅលើលោកពូ ស៊ឹម រ៉ុ កសិកររស់នៅក្នុងភូមិទួល ឃុំស្វាយរំពា ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ដែលដាំស្រូវផ្កាម្លិះទទួលបានទិន្នផលរហូតដល់ ៧,១២៤គីឡូក្រាម ក្នុងមួយហិចតា ដែលជាទិន្នផលមួយដ៏ខ្ពស់ សម្រាប់កសិករធ្វើស្រូវផ្កាម្លិះ ហើយគ្រប់ស្រែទាំងអស់គាត់មិនប្រើជីគីមី នឹងថ្នាំពុលឡើយ។ ជាលទ្ធផល លោកពូ ស៊ឹម រ៉ុ បានទទួលមេគោចំនួន ៥ក្បាយពីអង្គការសេដាក ហើយដែលការនេះបានលើកទឹកចិត្តគាត់ឲ្យខិតខំបន្ថែមទៀតក្នុងធ្វើស្រែតាមគោលការណ៍ធម្មជាតិ (មិនប្រើប្រាស់ជី និងថ្នាំគីមី) ព្រមទាំងផ្សព្វផ្សាយបន្តទៅកាន់កសិករដទៃ ឲ្យអនុវត្តទទួលបានជោគជ័យដូចរូបគាត់។







# គម្រោងប្រព័ន្ធចីរភាពកសិចំណីអាហារអាស៊ាន (ASEAN-SAS) របស់ អង្គការ GIZ

ការប្រើប្រាស់វត្ថុធាតុដើមគីមីសម្រាប់វិស័យកសិកម្មកំពុងមានការកើនឡើងយ៉ាងខ្លាំងគួរឲ្យកត់សម្គាល់ ជាពិសេសលើដំណាំស្រូវ ដែលជាដំណាំសំខាន់សម្រាប់ប្រទេសកម្ពុជា និងនៅតំបន់អាស៊ីអាគ្នេយ៍។ កសិករពឹងថាការប្រើប្រាស់សារធាតុគីមីសំយោគដូចជាថ្នាំ និងជី អាចជម្រុញផលិតភាពផលិតកម្ម លុបបំបាត់បញ្ហាសត្វល្អិត និងបង្កើនប្រាក់ចំណេញ។

តែទោះយ៉ាងណា អ្នកប្រើប្រាស់គម្បីស្វែងយល់ឱ្យបានច្បាស់អំពីរបៀបប្រើប្រាស់។ កាលណាការប្រើប្រាស់មិនបានត្រឹមត្រូវ សារធាតុទាំងនេះនឹងបង្កឱ្យមានបញ្ហាជាច្រើនរួមមាន ការខាតបង់ថវិកា ហានិភ័យដល់ប្រព័ន្ធអេកូឡូស៊ី និងគ្រោះថ្នាក់ដល់សុខភាពទាំងអ្នកប្រើប្រាស់ និងអ្នកបរិភោគ។ លើសពីនេះទៀត ការប្រើប្រាស់ថ្នាំ និងជីគីមីសំយោគបានបន្សល់កាកសំណល់គីមីនៅក្នុងចំណីអាហារដែលអាចជារនាំងដល់ការនាំចេញ។ យោងតាមរបាយការណ៍របស់អង្គការ FAO ឆ្នាំ២០១២ បានឲ្យដឹងថា រវាងឆ្នាំ ២០០៦ និងឆ្នាំ ២០១០ប្រទេសកម្ពុជាបាននាំចូលថ្នាំ និងជីគីមីសំយោគ ២៨៥ ដងសម្រាប់ក្នុងវិស័យកសិកម្ម ជាពិសេសដំណាំស្រូវ។

ដើម្បីដោះស្រាយ និងឆ្លើយតបនឹងបញ្ហាខាងលើ គម្រោងប្រព័ន្ធចីរភាពកសិចំណីអាហារអាស៊ាន (ASEAN-SAS) របស់ អង្គការ GIZ បានផ្តល់ជូននូវដំណោះស្រាយសន្តិសុខស្បៀងរយៈពេលវែងនៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់អាស៊ានទាំងមូលតាមរយៈការអភិវឌ្ឍគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងការសម្របសម្រួលថ្នាក់តំបន់សម្រាប់វិស័យកសិកម្មប្រកបដោយនិរន្តរភាព។ គម្រោងបានធ្វើកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធនានាដូចជា អ្នករៀបចំគោលនយោបាយអភិវឌ្ឍន៍ សហគ្រាសកសិកម្ម សមាគមកសិករ និងវិស័យឯកជនក្នុងការពង្រឹង និងផ្សព្វផ្សាយសង្វាក់ផលិតកម្ម និងតម្លៃ ដោយផ្តោតលើប្រធានបទបីសំខាន់ៗរួមមាន៖ ក្របខ័ណ្ឌគោលនយោបាយ បច្ចេកវិទ្យាផលិតកម្ម និងទំនាក់ទំនងទីផ្សារ។

នៅក្នុងឆ្នាំ ២០១៤ សេចក្តីណែនាំស្តីពីបទដ្ឋានគតិយុត្តិក្នុងការប្រើប្រាស់ និងការធ្វើពាណិជ្ជកម្មភ្នាក់ងារជីវសាស្ត្រ (BCA) ត្រូវបានអនុម័តដោយរដ្ឋមន្ត្រីរបស់ប្រទេសដែលជាសមាជិកអាស៊ានដោយមានការចូលរួមពីក្រុមអ្នកជំនាញក្នុងតំបន់ ក្នុងគោលបំណងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាសថ្នាំពុល និងជីកសិកម្ម។

នៅឆ្នាំ ២០១៥ វេទិកាថ្នាក់ជាតិស្តីពីបទដ្ឋានគតិយុត្តិ ការប្រើប្រាស់ និងការធ្វើពាណិជ្ជកម្មភ្នាក់ងារជីវសាស្ត្រ (BCA) ក្នុងវិស័យកសិកម្មនៅកម្ពុជាត្រូវបានរៀបចំឡើងចំនួនពីរលើកក្រោមកិច្ចសហការរវាងគម្រោង GIZ Cambodia និងHARVEST អនុវត្តដោយ Fintrac Inc និងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទក្នុងគោលបំណងផ្តល់ឱកាសដល់អ្នកពាក់ព័ន្ធផ្សេងៗក្នុងវស័យកសិកម្មចែករំលែកបទពិសោធន៍ដែលទទួលបានជោគជ័យក្នុងផលិតកម្មកសិកម្មដោយប្រើ BCA ដែលជាសរីរាង្គមានប្រយោជន៍ក្នុងការកំចាត់សមាសភាពចង្រៃដោយមិនពុលដល់សរីរាង្គមានប្រយោជន៍ដទៃទៀតក្នុងបរិយាកាស។ គេអាចប្រើ BCA បានច្រើនបំផុតនៅក្នុងបរិបទនៃយុទ្ធសាស្ត្រការគ្រប់គ្រងសត្វល្អិតចម្រុះ (IPM) ដែលសង្កត់ធ្ងន់ទៅលើការគ្រប់គ្រងសត្វល្អិតតាមបែបបង្ការដែលទាមទារការសង្កេតទៀងទាត់ និងប្រើប្រាសទាន់ពេលវេលាទៅលើដំណាំ។ BCA ត្រូវបានបែងចែកជាបួនប្រភេទរួមមាន៖

- ភ្នាក់ងារអតិសុខុមប្រាណកម្ចាត់សមាសភាពចង្រៃ (microbial ឬ MCA)
- សត្វមានប្រយោជន៍កម្ចាត់សមាសភាពចង្រៃ (macrobials)
- ថ្នាំកម្ចាត់សត្វល្អិតពាក់កណ្តាលគីមី Semiochemicals (ភាគច្រើនគឺផេរ៉ូម៉ូន (pheromones) កៃរ៉ូម៉ូន (kairomones) ។ល។)
- ផលិតផលធម្មជាតិ (ជាតុចម្រាញ់ពីរុក្ខជាតិ ឬ "ថ្នាំសម្លាប់សត្វល្អិតរុក្ខជាតិ" ផលិតផលផ្អាប់ (fermentation) និងផលិតផលផ្សេងទៀត)



*Trichoderma harzianum*

Trichoderma ជាផ្នែកមួយនៃ BCA ដែលអាចជួយកសិករក្នុងការដាំដំណាំបានល្អប្រសើរ បង្កើនប្រាក់ចំណូលគ្រួសារ កែប្រែចនាសម្ព័ន្ធដី ។ Trichoderma រស់នៅដោយសេរីនៅក្នុងដីកសិកម្ម និងធម្មជាតិ ហើយត្រូវបានអនុញ្ញាតឲ្យប្រើប្រាសក្នុងកសិកម្មសរីរាង្គ ដោយយោងតាមស្តង់ដាកសិកម្មសរីរាង្គអន្តរជាតិ ។ តាមការពិសោធន៍ Trichoderma មិនត្រឹមតែជួយកែប្រែគុណភាពដី ប្រឆាំងនឹងផ្សិតបង្កជំងឺដែលកើតចេញពីដីប៉ុណ្ណោះទេ ថែមទាំងអាចបាញ់លើស្លឹក និងប្រឡាក់គ្រាប់ពូជដើម្បីជម្រុញដំណុះ និងកំចាត់មេរោគលើគ្រាប់ពូជបានយ៉ាងមានប្រសិទ្ធិភាព។

នៅក្នុងឆ្នាំ ២០១៤ គម្រោងប្រព័ន្ធកសិចំណីអាហារប្រកបដោយចីរភាពអាស៊ាន (ASEAN-SAS) របស់ អង្គការ GIZ បានធ្វើពិសោធន៍ផ្សិតTrichodema លើដំណាំស្រូវ ដោយមានការសហការណ៍ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃដោយអគ្គនាយកដ្ឋានកសិកម្ម (GDA) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (សូមមើលតារាង) ។ ជាលទ្ធផលការប្រើ Trichoderma ជាមួយជីកំប៉ុស ឬជីលាមកសត្វអាចបង្កើនទិន្នផលបានរហូតដល់ទៅ ៦តោនក្នុងមួយហិកតា, ឫសស្រូវលូតលាស់បានល្អ ធន់ទៅនឹងជំងឺប្លាស់ និងគ្រោះរាំងស្ងួត។ លើសពីនេះទៀតធ្វើឲ្យស្រូវឆាប់ទុំទំបានប្រមូលផលជាងស្រូវដែលអត់ប្រើប្រាស់ផ្សិតTrichoderma។ GIZបានចងក្រងឯកសារណែនាំ(Manual) និងអាចជួយសម្រួលវគ្គបណ្តុះបណ្តាលលំអិតស្តីពីការ

(ត ទៅទំព័រទី ១៣)

(ត មកពីទំព័រទី ១២)

ប្រើប្រាស់ ផលិត និងផ្តល់ព័ត៌មានទីផ្សារTrichoderma។

នៅឆ្នាំ ២០១៦ គម្រោងនេះគ្រោងពិសោធន៍ផ្សិត Matarhizum ដែលត្រូវបានរកឃើញថាជា BCA មានប្រសិទ្ធិភាពប្រឆាំងពពួកសត្វល្អិត ជាពិសេសពពួកមមាចឆ្មោតស៊ីស្រូវ។ លើសពីនេះវេទិកាថ្នាក់ជាតិលើកទីបីស្តីពីបទដ្ឋានគតិយុត្តិ ការប្រើប្រាស់ និងការធ្វើពាណិជ្ជកម្មភ្នាក់ងារជីវសាស្ត្រ (BCA) ក្នុងវិស័យកសិកម្មគ្រោងនឹងរៀបចំនៅដើមឆ្នាំ ២០១៦ នៅរាជធានីភ្នំពេញ៕




## កម្មវិធី កម្ពុជាហាវែស របស់ USAID ជួយសហគមន៍បង្កើនការផ្គត់ផ្គង់បរិមាណគ្រាប់ពូជស្រូវគុណភាពល្អ

កម្ពុជាហាវែស (គម្រោងជួយដោះស្រាយភាពងាយរងគ្រោះនៅតាមជនបទ និងស្ថិរភាពប្រព័ន្ធអេកូឡូស៊ី) គឺជាកម្មវិធីសន្តិសុខស្បៀងចម្រុះ និង កម្មវិធីបម្រែបម្រួលអាកាសធាតុមានរយៈពេលប្រាំឆ្នាំកន្លះ ឧបត្ថម្ភដោយពលរដ្ឋអាមេរិកតាមរយៈគំនិតផ្តួចផ្តើមជួយចិញ្ចឹមអ្នកជំនាន់ក្រោយ (Feed the Future) និង បម្រែបម្រួលអាកាសធាតុសាកលរបស់សហរដ្ឋអាមេរិក ។ គោលដៅសំខាន់មួយក្នុងចំណោមគោលដៅសំខាន់ៗមួយចំនួនរបស់កម្មវិធី គឺបង្កើនភាពអាចរកបាននូវម្ហូបអាហារផ្តោតលើការពង្រឹងធាតុចូលនិងប្រព័ន្ធផលិតកម្មកសិកម្ម ការណែនាំប្រើប្រាស់នូវពូជដំណាំដែលមានលក្ខណៈល្អប្រសើរ និងបច្ចេកទេសកសិកម្មទំនើបជាងមុន ការធ្វើប្រពលវប្បកម្មទៅលើប្រព័ន្ធផលិតកម្ម នៅតាមជនបទ  និងការពង្រឹងក្របខណ្ឌគោលនយោបាយកសិកម្ម ។ (សម្រាប់ព័ត៌មាន ជាទូទៅបន្ថែមអំពីកម្មវិធីសូមចូលទៅកាន់គេហទំព័រ www.CambodiaHARVEST.org )

កម្មវិធីកម្ពុជាហាវែសធ្វើការក្នុងខ្សែចង្វាក់ផលិតកម្មស្រូវ និងជួយគាំទ្រកសិករដាំដុះស្រូវចំនួន ៥២.២៤៤ នាក់ ហើយភាគច្រើនជាកសិករដាំស្រូវខ្នាតតូច លើបញ្ហាមួយចំនួនដូចជា គុណភាពគ្រាប់ពូជ ផលិតកម្ម ការផ្សាភ្ជាប់ទំនាក់ទំនងទីផ្សារ និងការប្រើប្រាស់ថ្នាំកសិកម្មប្រកបដោយសុវត្ថិភាព។ បន្ថែមលើនេះកម្មវិធីក៏ធ្វើការជាមួយបណ្តា អ្នកផ្គត់ផ្គង់សម្ភារៈកសិកម្មក្នុងមូលដ្ឋាន រោងម៉ាស៊ីនកិនស្រូវ ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងអ្នកផ្តល់សេវាកម្មផ្សេងៗមួយចំនួនទៀត ដើម្បីដោះស្រាយបញ្ហារាំងស្ទះជាក់ស្តែងមួយចំនួនដែលបានជួបប្រទះនៅក្នុងខ្សែចង្វាក់ផលិតកម្ម។ វិធានការបន្សាំទៅនឹងការបម្រែបម្រួលអាកាសធាតុគឺជាចំណុចផ្តោតការយកចិត្តទុកដាក់ជាពិសេសមួយរបស់កម្មវិធី ។






(ត ទៅទំព័រទី ១៦)

# *Rice Moisture Tester*
# *Riceter f 521*




**All kinds of rice business people who are related with agriculture industry must have Kett Moisture Tester.**




## Why?

## One thing that rice farmers have to aviod is **Blind Drying!**

# Lose Profit

**Example :** *Target Moisture content 15% , Actual Moisture content 13%*




Even if a small measuring error happens by using unreliable moisture tester, it would bring a possibility of serious loss in the future when the rice would become merchandise rice.

So, using reliable moisture tester is more important than anything else.

# Lose Quality

### Excessive Drying




### Insufficient Drying




# Why choose Kett?

**1.** Kett has been researching & developing Moisture testers since 1946.




**2.** Not only Japan but also many countries have approved to use.
In Japan, Kett has been adopted as a Japanese standard moisture tester for more than 40 years.




## Measure the rice moisture at any time when you need it for drying rice, selling rice, and storing rice.
## Kett supports Cambodian Rice Policy by moisture tester.


Kett

***KETT ELECTRIC LABORATORY***
1-8-1 Minami-Magome Ota-Ku,Tokyo 143-8507 Japan
Tel.+81-3-3776-1121 Fax.+81-3-3772-3001
URL http://www.kett.co.jp/ E-mail overseas@kett.co.jp

**KETT customer service Cambodia**
**Mobile: +855 17838402**
S.I Building, #93, Preah Sihaknouk Blvd,
Phnom Penh, Kingdom of Cambodia

ក្រុមហ៊ុនអាយត្រេឌីង&ម៉ាស៊ីនើរីខ្ញុំអិធីឌី
i TRADING & MACHINERIES CORPORATION.,LTD

(ត មកពីទំព័រទី ១៣)

បញ្ហាមួយក្នុងចំណោមបញ្ហានានានៅក្នុងវិស័យស្រូវ គឺភាពអាចរកបាននូវគ្រាប់ពូជស្រូវមានគុណភាពល្អ និងពូជស្រូវសមស្របទៅនឹងលក្ខខណ្ឌដាំដុះផ្សេងៗគ្នា ការមានតម្រូវការទីផ្សារ និងការហូបចុកតាមគ្រួសារ។ កម្មវិធីកម្ពុជាហាវេស ធ្វើការយ៉ាងជិតស្និទ្ធ និងយ៉ាងទូលំទូលាយជាមួយសមាគមន៍កសិករផលិតគ្រាប់ស្រូវពូជ និងកសិករជំនាញផលិតគ្រាប់ស្រូវពូជ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ។ អត្ថបទខាងក្រោមគឺជាឧទាហរណ៍មួយនៃការងាររបស់កម្មវិធីដែលបានអនុវត្តកន្លងមក ។
ដូចបណ្ដាកសិករដំណាំស្រូវផ្សេងទៀតនៅក្នុងប្រទេសកម្ពុជាដែរ អ្នកនៅក្នុងភូមិគោកង្គួនមានបញ្ហាដែលត្រូវតស៊ូជំនះមួយគឺការស្វែងរកគ្រាប់ស្រូវពូជដែលមានគុណភាពល្អសម្រាប់យកមកដាំដុះ ។ ជាក់ស្ដែង គឺមិនថាពួកគាត់អនុវត្តបច្ចេកទេសដាំដុះបានល្អកម្រិតណានោះទេ តែទិន្នផល និងប្រាក់ចំណូលរបស់ពួកគាត់គឺនៅមានកម្រិតទាបដោយសារតែគុណភាពនៃធាតុចូល ពិសេសគឺគ្រាប់ពូជដែលពួកគាត់ដាំដុះនៅក្នុងដី ។

លោក **លឹម នូ** ជាកសិករដាំដុះស្រូវម្នាក់នៅភូមិគោកង្គួនស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជាបានមានប្រសាសន៍ថា "អ្នកនៅក្នុងសហគមន៍នេះគឺក្រៗណាស់ យើងបានគិតថាដើម្បីរកប្រាក់ចំណូលបន្ថែម មានតែការធ្វើការរួមគ្នា ដើម្បីដោះស្រាយបញ្ហានេះ" ។



*រូបថតដោយកម្មវិធី កម្ពុជាហាវេស*
លោកពូ **លឹម នូ** ប្រធានសហគមន៍កសិករផលិតស្រូវពូជ ឈរនៅមុខឃ្លាំងដែលសាងសង់ដោយជំនួយរបស់កម្មវិធី។ ឃ្លាំងនេះជួយការពារស្រូវពូជរបស់សហគមន៍ និងជួយឲ្យសមាជិកសហគមន៍អាចលក់ស្រូវរយៈពេលពីរបីខែក្រោយពេលប្រមូលផល ពេលតម្លៃ និងតម្រូវការកើនឡើងខ្ពស់។

នៅក្នុងឆ្នាំ២០១២ សមាជិកនៅក្នុងសហគមន៍អភិវឌ្ឍកសិកម្មចំនួន ១៥ នាក់ បានសហការគ្នាផលិតគ្រាប់ពូជស្រូវ។ ដោយមានការជួយគាំទ្រពីសំណាក់កម្មវិធីកម្ពុជាហាវេស ក្រុមដែលមានគ្នា ១៥នាក់នេះបានធ្វើការរួមគ្នា ផលិតស្រូវពូជ បួនពូជ ដែលមានតម្រូវការខ្ពស់នៅលើទីផ្សារ។ ពួកគាត់បានលក់គ្រាប់ពូជស្រូវ ទៅឲ្យកសិករនៅក្នុងសហគមន៍របស់ពួកគាត់ ដែលកំពុងមានតម្រូវការខ្លាំងនូវគ្រាប់ពូជស្រូវមានគុណភាព ។ លោកពូ លឹម នូ បានមានប្រសាសន៍ថា "អ្នកភូមិទីនេះស្ទើរតែគ្រប់គ្នាមកទិញពូជពីក្រុមយើងយកទៅដាំដុះ ហើយពួកគេទទួលបានលទ្ធផលល្អពិតមែន" ។
ជាមធ្យមកសិករឃើញផលិតកម្មស្រូវរបស់ពួកគាត់កើនបាន ៧៥ ភាគរយ នៅពេលពួកគាត់ប្រើពូជដែលមានគុណភាពល្អ ព្រមជាមួយនឹងការអនុវត្តតាមបច្ចេកទេសដាំដុះល្អៗរបស់កម្មវិធី។

កម្មវិធី កម្ពុជាហាវេស
បានជួយសហគមន៍ផលិតគ្រាប់ស្រូវពូជចំនួនបីដើម្បីបង្កើនសមត្ថភាពរបស់ពួកគេឲ្យកាន់តែល្អបន្ថែមទៀត។
តាមរយៈការចូលរួមផ្ដល់ទុនបដិភាគពីថវិកាបច្ចេកវិទ្យារបស់កម្មវិធី ពួកគេបានសង់នូវឃ្លាំងស្ដុកគ្រាប់ពូជស្រូវដែលមានសមត្ថភាពស្ដុកបានរហូតដល់ ៤៥ តោន ក្នុងឃ្លាំងនីមួយៗ។ ក្រោមលក្ខខណ្ឌការដាក់ទុនវិនិយោគរួមគ្នា ក្រុមកសិករផ្ដល់នូវដីសម្រាប់សាងសង់ឃ្លាំង ចំណែកឯកម្មវិធីកម្ពុជាហាវេសជួយទៅលើថ្លៃសាងសង់ឃ្លាំង។
ឃ្លាំងដែលបានសាងសង់រួច អនុញ្ញាតឲ្យសមាជិកសហគមន៍យកគ្រាប់ស្រូវ ឬគ្រាប់ពូជស្រូវរបស់ពួកគាត់ទៅរក្សាទុកនៅទីនោះ និង លក់ចេញនៅខែបន្ទាប់ៗក្រោយពីច្រូតកាត់ នៅពេលដែលតម្លៃបានខ្ពស់ និងលក្ខខណ្ឌទីផ្សារមានភាពអំណោយផល។
ឃ្លាំងទាំងបីនេះក៏បានជួយការពារគ្រាប់ស្រូវពូជមិនឲ្យខូចគុណភាពនៅចន្លោះពេលរក្សាទុកមុនយកវាទៅដាំដុះផងដែរ ។

ចាប់តាំងពីបានសង់ឲ្យមាននូវឃ្លាំងផ្ទុកស្រូវក្នុងឆ្នាំ ២០១៤ មក គិតមកទល់ពេលនេះសហគមន៍ផលិតស្រូវពូជទាំងបីទទួលបានចំណូលពីការលក់ស្រូវពូជជាទឹកប្រាក់សរុបស្មើនឹង ៧៦.៨៨២ ដុល្លា គិតជាកំណើនសរុបស្មើនឹង ៤៥២ ភាគរយ លើសទិន្នន័យដើមគ្រា ដែលកំណើននេះអាចនិយាយបានថាគឺមកពីមានឃ្លាំងស្ដុកស្រូវនេះតែម្ដង។ លោកពូ លឹម នូ បានបន្ថែមទៀតថា "មានឃ្លាំងនេះគឺមានសារៈសំខាន់ខ្លាំងណាស់ បើគ្មានវាទេយើងនឹងមានការពិបាកក្នុងការផលិតគ្រាប់ពូជស្រូវឲ្យបានល្អ" ៕



# ស្វែងយល់អំពីប្រព័ន្ធធានារ៉ាប់រងកសិកម្ម ខ្នាតតូចកម្ពុជា

ប្រព័ន្ធធានារ៉ាប់រងកសិកម្មខ្នាតតូចកម្ពុជា គឺប្រព័ន្ធជួយគ្នាទៅវិញទៅមកក្នុងចំណោមកសិករ ដើម្បីទប់ទល់នឹងហានិភ័យផ្សេងៗ។ ប្រព័ន្ធនេះបង្កើតឡើង និងអនុវត្តដោយ អង្គការសេដាកសហការជាមួយសមាគមកសិករក្រោមជំនួយថវិកា និងបច្ចេកទេសមកពីមូលនិធិអាក់មៀ (Achmea) ប្រទេសហូឡង់។

**ចក្ខុវិស័យ៖** ផលិតកម្មកសិកម្មរបស់កសិករត្រូវបានគាំពារដើម្បីទប់ទល់នឹងគ្រោះមហន្តរាយធម្មជាតិ និងហានិភ័យផ្សេងៗដែលកើតឡើងដោយចៃដន្យ ដើម្បីធានាបាននូវចីរភាពប្រាក់ចំណូល និងមុខរបរចិញ្ចឹមជីវិត។

**បេសកកម្ម:**
- ផ្តល់សេវាកម្មធានារ៉ាប់រងផលិតកម្មកសិកម្មដើម្បីការពារលើការខូចខាតដែលកើតឡើងដោយគ្រោះមហន្តរាយធម្មជាតិ ឬហានិភ័យផ្សេងៗ។
- លើកកម្ពស់កម្រិតជីវភាពគ្រួសារកសិករតាមរយៈការផ្តល់ប្រឹក្សាបច្ចេកទេសកសិកម្មដែលធន់នឹងបម្រែបម្រួលអាកាសធាតុ និងវិធីសាស្ត្រក្នុងការត្រៀមបង្ការ និងគ្រប់គ្រងហានិភ័យ។

**តើធានារ៉ាប់រងស្រូវជាអ្វី?**
ធានារ៉ាប់រងស្រូវគឺជាមធ្យោបាយគាំពារកសិករពីការបាត់បង់ប្រាក់ចំណូល ដែលបណ្តាលមកពីការខូចខាត ផលិតកម្មស្រូវដោយសារហានិភ័យផ្សេងៗដែលមិនអាចគ្រប់គ្រងបាន។



**តើនរណាខ្លះអាចទិញធានារ៉ាប់រងស្រូវបាន?**
នៅដំណាក់កាលសាកល្បង ប្រព័ន្ធធានារ៉ាប់រងកសិកម្មខ្នាតតូចកម្ពុជានឹងផ្តល់អាទិភាពដល់សមាជិកកម្មវិធីការអភិវឌ្ឍន៍អាស្រ័យខ្លួនឯង (ស២២)របស់អង្គការសេដាក។ បន្ទាប់ពីការសាកល្បងទទួលបានជោគជ័យ សហគមន៍ នឹងបើកចំហរគ្រប់កសិករទាំងអស់ទូទាំងប្រទេស។

**តើកសិករត្រូវឲ្យទិញធានារ៉ាប់រងស្រូវលើផ្ទៃដីស្រែទាំងអស់ឬ?**
ប្រាកដណាស់។ ដើម្បីតម្លាភាព យើងលើកទឹកចិត្តសមាជិកស២២ទាំងអស់ឲ្យទិញធានារ៉ាប់រងសម្រាប់លើផ្ទៃដីស្រែទាំងអស់ដែលមាន (វាគឺជាកាតព្វកិច្ច)។

**តើកសិករអាចទិញធានារ៉ាប់រងបាននៅពេលណា?**
កសិករអាចទិញធានារ៉ាប់រងស្រូវបាននៅចន្លោះថ្ងៃទី០១ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ជារៀងរាល់ឆ្នាំ។ សហគមន៍យើងខ្ញុំរក្សាសិទ្ធិក្នុងការកែសម្រួល ឬពន្យាពេលលក់ផលិតផល។



**ផលិតផល និងសេវាកម្ម**
នៅដំណាក់កាលសាកល្បងសហគមន៍យើងខ្ញុំ ផ្តល់ជូននូវសេវាកម្មទៅដល់សមាជិករបស់ខ្លួនដូចខាងក្រោមៈ
- សេវាធានារ៉ាប់រងស្រូវសម្រាប់ហានិភ័យដោយគ្រោះធម្មជាតិមានដូចជា គ្រោះរាំងស្ងួត និងទឹកជំនន់។
- សេវាកម្មបច្ចេកទេសស្តីពីវិធីសាស្ត្រត្រៀមបង្ការ និងការពារហានិភ័យ។

**ផលប្រយោជន៍**
តាមរយៈការទិញធានារ៉ាប់រងស្រូវ សមាជិកនឹងទទួលបានផលប្រយោជន៍សំខាន់ៗដូចជា៖
- ការទូរទាត់សំណងលើការខូចខាត និងបាត់បង់ផលិតកម្មស្រូវ អាចជាលុយ ឬពូជស្រូវ។
- ទទួលបានសេវាកម្មប្រឹក្សាយោបល់ស្តីពីបច្ចេកទេសកសិកម្ម វិធីសាស្ត្រត្រៀមបង្ការ ការកាត់បន្ថយ និងគ្រប់គ្រងហានិភ័យ។
- ការជួយគ្នាទៅវិញទៅមកក្នុងចំណោមអ្នកធ្វើស្រែដូចគ្នា។



# បទពិសោធន៍ក្នុងការធ្វើកិច្ចសន្យាផលិតកម្មកសិកម្ម ( Contract Farming ) ផលិត និងផ្គត់ផ្គង់ស្រូវសរីរាង្គរវាងសហគមន៍កសិកម្មចំនួន ៨ និង ក្រុមហ៊ុនអេមរុ រ៉ាយស៍ (ខេមបូឌា) ដែលគាំទ្រដោយគម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា ( SCCRP )

## ១.សេចក្តីផ្តើម ឬប្រវត្តិ

ដោយមានការឧបត្ថម្ភគាំទ្រពីគម្រោង "គាំទ្រពាណិជ្ជូបនីយកម្មស្រូវ-អង្ករកម្ពុជា" របស់ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សហការណ៍ជាមួយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រោមការជួយឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារបារាំងដើម្បីការអភិវឌ្ឍន៍ (AFD) ក្រុមហ៊ុន អេមរុ រ៉ាយស៍ បានចាប់ផ្តើមបង្កើតភាពជាដៃគូរជាមួយសហគមន៍កសិកម្មចំនួន ៥ នៅក្នុងឆ្នាំ ២០១៣ និងកើនឡើងដល់ ៨ ចាប់ពីឆ្នាំ ២០១៤ ក្នុងខេត្តព្រះវិហារ។

នៅក្នុងរដូវកាលឆ្នាំ២០១៤ សហគមន៍កសិកម្មទាំង ៨ បានធ្វើកិច្ចសន្យាផលិតកម្មកសិកម្ម ជាមួយក្រុមហ៊ុន អេមរុ រ៉ាយស៍ ក្នុងការផលិតនិងផ្គត់ផ្គង់ស្រូវសរីរាង្គស្របតាមស្តង់ដារបស់សហភាពអឺរ៉ុប និង សហរដ្ឋអាមេរិក បរិមាណចន្លោះពី ១,៨០០-២,៣០០ តោន។ ជាលទ្ធផលបរិមាណស្រូវសរីរាង្គជិត ១,៥០០ តោន ដែលមានការបញ្ជាក់ទទួលស្គាល់គុណភាពស្របតាមស្តង់ដាដែលបានព្រមព្រៀងគ្នានៅក្នុងកិច្ចសន្យាផលិតកម្មកសិកម្ម ត្រូវបានផ្គង់ផ្គង់ដល់ក្រុមហ៊ុន អេមរ៉ុ រាយស៍។

ដើម្បីធ្វើឲ្យរឹងមាំនូវខ្សែសង្វាក់ផ្គត់ផ្គង់ស្រូវសរីរាង្គប្រកបដោយនិរន្តភាពក្នុងខេត្តព្រះវិហារ នៅក្នុងឆ្នាំ ២០១៥ អនុស្សារណៈមួយរវាងក្រុមហ៊ុន អេមរុ រ៉ាយស៍ សហគមន៍កសិកម្មទាំង ៨ ក្នុងខេត្តព្រះវិហារ និង គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវ-អង្ករកម្ពុជា ត្រូវបានរៀបចំនិងចុះហត្ថលេខាកាលពីថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥។ យោងទៅតាមខ្លឹមសារនៃអនុស្សារណៈ កាលពីថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៥ ក្រុមហ៊ុន អេមរុ រ៉ាយស៍ បានចុះហត្ថលេខាលើកិច្ចសន្យាផលិតកម្មកសិកម្មជាមួយសហគមន៍កសិកម្មទាំង ៨ ដើម្បីផលិតនិងផ្គត់ផ្គង់ស្រូវសរីរាង្គស្របតាមស្តង់ដាសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក បរិមាណ ៣,៣៥៩.២៥ តោន (ស្រូវក្រអូប ៣,១៤៥.១០ តោន និងស្រូវ ស ២១៤.១៥ តោន)។

## ២. ម៉ូដែលនៃកិច្ចសន្យា




(ត ទៅទំព័រទី ១៩)

(ត មកពីទំព័រទី ១៨)






## ៣. ខ្លឹមសារនៃកិច្ចសន្យាផលិតកម្មកសិកម្ម

កិច្ចសន្យាផលិតកម្មកសិកម្មស្ដីអំពីការផលិតនិងការផ្គត់ផ្គង់ស្រូវសរីរាង្គរវាងក្រុមហ៊ុនអេមរុ រ៉ាយស៍ និងសហគមន៍កសិកម្មចំនួន ៨ នៅក្នុងខេត្តព្រះវិហារ គឺជាកិច្ចសន្យាដែលត្រូវបានរៀបចំឡើង មួយឆ្នាំម្តង។ កិច្ចសន្យានោះមានទាំងអស់ ១២ ប្រការរួមមានៈ កម្មវត្ថុកិច្ចសន្យា ថេរវេលាក្នុងការអនុវត្តន៍ សិទ្ធិនិងកាតព្វកិច្ចរបស់ភាគីអ្នកផលិត សិទ្ធិនិងកាតព្វកិច្ចរបស់ភាគីអ្នកទិញ ការប្រមូលផលនិងការដឹកជញ្ជូន គុណភាពស្រូវ ការកំណត់តម្លៃស្រូវ ការទូទាត់ប្រាក់ ករណីប្រធានសក្តិ ការបញ្ចប់កិច្ចសន្យា ការដោះស្រាយវិវាទ និង ការបង្កើតកិច្ចសន្យាថ្មីនិងភាសា។ រាល់ខ្លឹមសារលម្អិតនៃ ប្រការនីមួយៗ ត្រូវបានស្នើរឡើង ពិភាក្សា និងព្រមព្រៀងគ្នានៅក្នុងដំណើការសម្របសម្រួលនិងរៀបចំកិច្ចសន្យាផលិតកម្មកសិម្ម។

## ៤. លទ្ធផលនៃការអនុវត្តន៍កិច្ចសន្យាផលិតកម្មកសិកម្ម

សម្រាប់រដូវកាលឆ្នាំ ២០១៤ សហគមន៍អភិវឌ្ឍន៍កសិកម្មទាំង ៨
បានផ្គត់ផ្គង់ស្រូវសរីរាង្គដែលមានការបញ្ជាក់ស្របតាមស្តង់ដារបស់សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិកដោយក្រុមហ៊ុន អេកូសែក (ECOCERT) បរិមាណជិត ១,៥០០ តោន ដល់ក្រុមហ៊ុន អេមរុ រ៉ាយស៍។ ដោយយោងទៅតាមគុណភាព ស្រូវសរីរាង្គមានតម្លៃចន្លោះពី ១,១៧០ រៀល/គ.ក្រ ទៅ ១,៤៥០ រៀល/គ.ក្រ (តម្លៃជាមធ្យមគឺ ១,២៥៣.៥៣ រៀល/គ.ក្រ)។

## ៥.អត្ថប្រយោជន៍នៃកិច្ចសន្យាផលិតកម្មកសិកម្ម

តាមរយៈនៃការអនុវត្តន៍កិច្ចសន្យាផលិតកម្មកសិកម្មនេះ ភាគីទាំងពីរទទួលបានផលប្រយោជន៍ដូចខាងក្រោមៈ
ភាគីអ្នកផលិត

- ធានាបាននូវបរិមាណ គុណភាព និងតម្លៃស្រូវ
- ទទួលបានថ្លៃបុព្វលាភសម្រាប់គុណភាពស្រូវសរីរាង្គ ដែលខ្ពស់ជាងតម្លៃស្រូវធម្មតា
- ទទួលបាននូវការបណ្តុះបណ្តាលបច្ចេកទេសអំពីការពិនិត្យគុណភាពស្រូវបឋមដល់គណៈកម្មការសហគមន៍កសិកម្មមុនពេល ប្រមូលផលពីភាគីអ្នកទិញ
- មិនបាច់ចំណាយក្នុងការលើកដាក់ និងដឹកជញ្ជូនស្រូវពីទីកន្លែងប្រមូលផ្តុំស្រូវទៅរោងម៉ាស៊ីនកិនស្រូវ
- ទទួលបានសំបកបារ៉ពីភាគីអ្នកទិញដោយពុំគិតថ្លៃ

ភាគីអ្នកទិញ

- ធានាបាននូវបរិមាណ និងគុណភាពស្រូវដែលផ្គត់ផ្គង់ដោយភាគីអ្នកផលិត នៅមុនរដូវកាលដាំដុះ
- ធានាបាននូវការគោរពតាមស្តង់ដាស្រូវសរីរាង្គដោយភាគីអ្នកផលិត

## ៦. សេចក្តីសន្និដ្ឋាន

កិច្ចសន្យាផលិតកម្មកសិកម្មក្នុងការផលិត និងផ្គត់ផ្គង់ស្រូវសរីរាង្គរវាងក្រុមហ៊ុន អេមរុ រ៉ាយស៍ និងសហគមន៍កសិកម្មចំនួន ៨ នៅក្នុងខេត្តព្រះវិហារគឺជាកិច្ចសន្យាមួយដែលជោគជ័យដោយយោងទៅលើ បរិមាណ គុណភាព និងតម្លៃ។ ក្នុងការអនុវត្តន៍កិច្ចសន្យានេះ ភាគីទាំងពីរបានអនុវត្តទៅតាមកិច្ចព្រមព្រៀងដែលមានចែងក្នុងកិច្ចសន្យា។ ក្នុងករណីដែលមានបញ្ហាកើតឡើង (ស្រូវមួយចំនួនមានគុណភាពមិនស្របតាមកិច្ចព្រមព្រៀងដែលមានចែងក្នុងកិច្ចសន្យា) ភាគីទាំងពីរបានព្យាយាមចរចា និងស្វែងរកដំណោះស្រាយទាំងអស់គ្នា។
ដោយសារតែទទួលបានលទ្ធផលល្អក្នុងរដូវកាលឆ្នាំ ២០១៤ ភាគីទាំងពីរបានសម្រេចរៀបចំ និងចុះហត្ថលេខាលើអនុស្សរណៈ "សម្រាប់ការអភិវឌ្ឍន៍ខ្សែសង្វាក់ផ្គត់ផ្គង់ស្រូវសរីរាង្គប្រកបដោយនិរន្តរភាពក្នុងខេត្តព្រះវិហារ" កាលពីថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ ដើម្បីផលិត និងផ្គត់ផ្គង់ស្រូវសរីរាង្គបរិមាណយ៉ាងហោចណាស់ ២,៥០០ តោន នូវប្រភេទស្រូវក្រអូបសរីរាង្គ និងស្រូវសសរីរាង្គបរិមាណ ១,000 តោន សម្រាប់រដូវកាលឆ្នាំ ២០១៥ និងបរិមាណមិនតិចជាង ៣,៥០០ តោន សម្រាប់ស្រូវក្រអូបសរីរាង្គ និងប្រភេទស្រូវសសរីរាង្គបរិមាណ ២,000 តោន សម្រាប់រដូវកាលឆ្នាំ ២០១៦។
ដោយយោងទៅតាមអនុស្សរណៈ និងស្ថានភាពជាក់ស្តែងរបស់សហគមន៍ទាំង ៨
ភាគីទាំងពីរបានចុះហត្ថលេខាលើកិច្ចសន្យាផលិតកម្មកសិកម្មកាលពីថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៥ ក្នុងការផលិតនិងផ្គត់ស្រូវសរីរាង្គ បរិមាណសរុប ៣,៣៥៩.២៥ តោន (ស្រូវក្រអូប ៣,១៤៥.១ តោន)៕

## ព័ត៌មានអំពី វឌ្ឍនភាពនៃ ការអភិវឌ្ឍន៍ម៉ាកយីហោអង្ករកម្ពុជា "ការរៀបចំម៉ាកអង្ករួម និងការជម្រុញផ្សព្វផ្សាយម៉ាកអង្ករកម្ពុជា"

បរិមាណនៃការនាំចេញអង្កររបស់កម្ពុជា កំពុងមានកំណើនគួរឲ្យកត់សំគាល់ទោះបីកម្ពុជាពុំអាចសម្រេចគោលដៅ ១លានតោន ឆ្នាំ២០១៥ក៏ដោយ។ ជាមួយគ្នានេះដែរ យើងសង្កេតឃើញថា អង្ករកម្ពុជាមិនទាន់ទទួលបានភាពជឿជាក់ និងទទួលស្គាល់ឲ្យបានទូលំទូលាយ ជាពិសេសពីសំណាក់អ្នកបរិភោគផ្ទាល់នៅទីផ្សារអន្តរជាតិប៉ុន្មាននោះទេ ដែលវាផ្ទុយពីភាពល្បីល្បាញរបស់អង្ករកម្ពុជាតាមរយៈការឈ្នះជាអង្ករល្អបំផុតរបស់ពិភពលោក (World's Best Rice Award) បីឆ្នាំជាប់ៗគ្នា ២០១២ ២០១៣ និង២០១៤។ ម្យ៉ាងវិញទៀត តំលៃលក់ជាក់ស្តែងរបស់អង្ករនៅពុំទាន់មានលំនឹង និងល្អសាកសមនឹងគុណភាពពិតរបស់អង្ករកម្ពុជានៅឡើយទេ។



អាស្រ័យហេតុនេះ សហព័ន្ធស្រូវអង្ករកម្ពុជា តាមរយៈគណៈកម្មាធិការជម្រុញ និងផ្សព្វផ្សាយទីផ្សារអន្តរជាតិ (GMP ExCo) របស់ខ្លួន ដោយមានការសហការ និងជ្រោមជ្រែងពីក្រសួងស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងពាណិជ្ជកម្ម IFC និងគំរោងSNEC/AFD កំពុងរៀបចំបង្កើតម៉ាកអង្ករួមមួយសម្រាប់អង្ករក្រអូបប្រណិតរបស់កម្ពុជាជាមុនសិន។

ការបង្កើតម៉ាកអង្ករសម្រាប់អង្ករក្រអូបប្រណិតនេះ គ្រោងនឹងបញ្ចប់នាដើមឆ្នាំ២០១៦ខាងមុខនេះ ហើយវាក៏ជាលើកដំបូង ដែលកម្ពុជានឹងមានម៉ាកអង្ករជាតិពិតប្រាកដ ហើយផ្តើមចេញពីអង្ករក្រអូបប្រណិតជាមុនសិន ព្រោះវាជាចំណុចខ្លាំងរបស់កម្ពុជា ក្នុងការផ្សព្វផ្សាយ និងឆាប់ទទួលបានភាពទុកចិត្ត និងពេញនិយមពីសំណាក់អ្នកបរិភោគទូទាំងពិភពលោក។

ក្រៅពីការចុះបញ្ជីកម្មសិទ្ធិបញ្ញាជាតិ និងអន្តរជាតិ ការរៀបចំម៉ាកអង្ករក្រអូបប្រណិតនេះ មានពីរផ្នែកសំខាន់ធំៗគឺ៖ ផ្នែកទី១ ទាក់ទិននឹងការកំណត់អត្តសញ្ញាណរួមមានឈ្មោះពាណិជ្ជសញ្ញា និងយុទ្ធសាស្ត្រផ្សព្វផ្សាយជាមួយនឹងម៉ាកអង្ករនេះសម្រាប់ទីផ្សារដែលកំពុងមានសក្តានុពលចំនួន៦ និងផ្នែកទី២ ទាក់ទិននឹងការរៀបចំនីតិវិធីក្នុងការចុះឈ្មោះប្រើប្រាស់ ការប្រើប្រាស់ ការតាមដាន នឹងគ្រប់គ្រងលើអ្នកប្រើប្រាស់។ តាមរយៈការរៀបចំម៉ាកអង្ករក្រអូបប្រណិតរបស់កម្ពុជា និងការជម្រុញផ្សព្វផ្សាយនាឆ្នាំខាងមុខនេះ យើងសង្ឃឹមថាអង្ករកម្ពុជានឹងទទួលបានការទទួលស្គាល់ ពេញនិយម និងជឿជាក់យ៉ាងទូលំទូលាយ ព្រមទាំងទទួលបានតម្លៃខ្ពស់ពីទីផ្សារអន្តរជាតិ៕

## ព័ត៌មានអំពីស្ថានភាពតម្រូវការ និង ផែនការអភិវឌ្ឍន៍ពូជស្រូវកម្ពុជា

### "ស្ថានភាពនៃវិស័យពូជស្រូវ"

ស្ថានភាពពូជស្រូវបច្ចុប្បន្នមិនទាន់មានភាពមិនស្ថិតស្ថេរ និងភាពច្បាស់លាស់ ទាំងគុណភាព ទាំងបរិមាណ នេះដោយសារតែស្ថានភាពផលិត កត្តាផលិត កត្តាចែកចាយ និងកត្តាប្រើប្រាស់។

កត្តាផលិត គឺមិនទាន់មានភាពទុកចិត្តណាមួយលើការវិនិយោគរបស់វិស័យឯកជនលើផលិតកម្មពូជ ទាំង សម្ភារៈ បច្ចេកទេស និងការអភិវឌ្ឍន៍ប្រភេទពូជនៅឡើយ។

កត្តាចែកចាយ ពោលគឺពុំទាន់មានពូជគ្រប់គ្រាន់ មានគុណភាព និងបរិមាណសម្រាប់ ការដាំដុះក្នុងលក្ខណៈអាជីវកម្មនៅឡើយ ពោលគឺពុំមានប្រព័ន្ធចែកចាយ ពុំមានការ ចូលរួមធ្វើទីផ្សារពូជពីវិស័យឯកជននៅមានកម្រិត និងពុំទាន់មានប្រព័ន្ធត្រួតពិនិត្យពូជស្រូវ (ច្បាប់ផលិត និងចែកចាយពូជ) ដូចប្រទេសជិតខាង។

កត្តាប្រើប្រាស់ កសិករមិនទាន់ទទួលយកនៅការប្រើប្រាស់ពូជល្អនៅឡើយដោយសា ទីមួយកសិករមួយចំនួនពុំមានគំនិតតានមដាមស្រូវជាលក្ខណៈអាជីវកម្មពោលគឺពួកគាត់គ្រាន់តែដាំដុះជាលក្ខណៈប្រើប្រាស់ក្នុងគ្រួសារដូចនេះពួកគាត់ពុំគិតគូរពីការយក់ ពូជសុទ្ធល្អទេគឺគ្រាន់តែជ្រើសរើសស្រូវដែលល្អទុកធ្វើពូជបន្តបន្ទាប់។ ទី ២ កសិករ លេងមានទំនុកចិត្តលើកទីផ្សារពីព្រោះក្នុងស្ថានភាពបច្ចុប្បន្នពួកគាត់ឃើញថាទោះ គាត់យកពូជសុទ្ធ ឬពូជមិនសុទ្ធក៏តម្លៃនៅដូចខ្នាដ៏ដែល នេះដោយសារការយល់ដឹង អំពីការដាំស្រូវជាលក្ខណៈពាណិជ្ជកម្មរបស់កសិករនៅមានកម្រិតទាប។

សរុបមក ដើម្បីដោះស្រាយខាងលើទាមទារឲ្យមានផែនការច្បាស់លាស់ ដូចជា ផែនការទីផ្សារ ផែនការផលិត និងប្រមូលទិញ ធ្វើយ៉ាងណាអោយវិស័យមានភាពរឹង មាំ នឹងដើម្បីលើកកម្ពស់ទំនុកចិត្តដល់វិស័យឯកជនដើម្បីវិនិយោគ និងទំនុកចិត្តដល់កសិករអ្នកប្រើប្រាស់ពូជទទួលយកពូជល្អទៅប្រើប្រាស់ដើម្បីបង្កើនតម្រូវការលើទី ផ្សារពូជដែលជាចលករជំរុញ និងអភិវឌ្ឍន៍ពូជស្រូវ។

ដូចនេះសហព័ន្ធស្រូវអង្ករកម្ពុជា មានផែនការដោយផ្អែកលើទីផ្សារបានរៀបចំផែនការតម្រូវការពូជ ទាំងបរិមាណ និង ប្រភេទដើម្បីលើកផែនការផលិតដើម្បីជម្រុញឲ្យភ្នាក់ងារពាក់ព័ន្ធអនុវត្ត ហើជម្រុញ ការសិក្សាវិនិយោគលើវិស័យពូជ ការបង្កើតប្រព័ន្ធត្រួតពិនិត្យ (ច្បាប់ពូជ) ការធ្វើពាណិជ្ជកម្មពូជ៕



## បញ្ជីឈ្មោះក្រុមហ៊ុនអ្នកនាំចេញ និងរោងម៉ាស៊ីនកិនស្រូវដែលបានចុះហត្ថលេខា លើ ក្រមសីលធម៌( ស.អ.ក )

| ល/រ | ឈ្មោះក្រុមហ៊ុន |
|---|---|
| ០១ | Soma Group ( President ) |
| ០២ | Nikoline Investment |
| ០៣ | Battambang Rice Investment |
| ០៤ | Carma Rice Limited |
| ០៥ | Ean Heang Import Export |
| ០៦ | City Rice Import Export Co., ltd |
| ០៧ | H.S Rice Co. , Ltd |
| ០៨ | Kampong Thom Rice Mill Limited |
| ០៩ | Sok Keo Import Export Co., Ltd |
| ១០ | Bayong Cereal Co., Ltd |
| ១១ | T .O.T ( trust our Trade Co., Ltd |
| ១២ | Hung Hiep Cambodia Co., Ltd |
| ១៣ | Thmor Korl Rice Import Export Co., Ltd |
| ១៤ | Indochina Rice Mill Limited |
| ១៥ | W.K.R Trading |
| ១៦ | Vong Bun Heng Import Export Co., Ltd |
| ១៧ | Uni-Natural Co., Ltd |
| ១៨ | Amru Rice Cambodia Co., Ltd |
| ១៩ | Amru and hanwa international Co., Ltd |
| ២០ | Mekong Oryza Traing |
| ២១ | CK rice Trading Co., Ltd |
| ២២ | Signature of Asia Co., Ltd |
| ២៣ | Cambodia Lisshine International Co., Ltd |
| ២៤ | Golden Daun Keo rice Mill Co., Ltd |
| ២៥ | Jasmine Factory Co., Ltd |
| ២៦ | Cavifood Cambodia Co., Ltd |
| ២៧ | Golden Rice Cambodia Co., Ltd |
| ២៨ | Mekong Agro (kh) Industrial Limited |
| ២៩ | SScorp Cambodia Co., Ltd |
| ៣០ | Men Sarun Import Export Co., Ltd |
| ៣១ | Crystal Rice Kampuchea Co., Ltd |
| ៣២ | Lim Heng Leap Trading Co., ltd |
| ៣៣ | Palm Rice Co., Ltd |
| ៣៤ | Baitan Kampuchea Co., Ltd |
| ៣៥ | Lork Eak Heng Sek Meas Rice Co., Ltd |
| ៣៦ | Tech Soon Agro-Industry Co., Ltd |
| ៣៧ | Kong Hour Rice Mill Limited |
| ៣៨ | Camshin Xin Xi Group |

| ល/រ | រោងម៉ាស៊ីនកិនស្រូវ |
|---|---|
| ៣៩ | រោងម៉ាស៊ីនកិនស្រូវឈិត ប៊ុន ថន |
| ៤០ | រោងម៉ាស៊ីនកិនស្រូវឈុន ធំ |
| ៤១ | រោងម៉ាស៊ីនកិនស្រូវ នង់ស្រ៊ឹម |
| ៤២ | រោងម៉ាស៊ីនកិនស្រូវ យិនម៉ាន់ |
| ៤៣ | រោងម៉ាស៊ីនកិនស្រូវ ភាគ ឈួយ |
| ៤៤ | រោងម៉ាស៊ីនកិនស្រូវ ស៊ីវ ឡាយ |
| ៤៥ | រោងម៉ាស៊ីនកិនស្រូវ កៅ ង៉ែត |
| ៤៦ | រោងម៉ាស៊ីនកិនស្រូវ ចាំង ម៉េង |
| ៤៧ | រោងម៉ាស៊ីនកិនស្រូវ ភូកុក គី |
| ៤៨ | រោងម៉ាស៊ីនកិនស្រូវ ហ៊ួយ មាន |
| ៤៩ | រោងម៉ាស៊ីនកិនស្រូវ ថនជា |
| ៥០ | សហគមន៍អភិវឌ្ឍកសិកម្ម និគម ព្រះសិហនុ |
| ៥១ | រោងម៉ាស៊ីនកិនស្រូវ ជិនមី |
| ៥២ | រោងម៉ាស៊ីនកិនស្រូវ ជា ហ៊ាប |
| ៥៣ | សម្ព័នសមាគមសហគ្រាសធុនតូចនឹងមធ្យមកម្ពុជា |
| ៥៤ | រោងម៉ាស៊ីនកិនស្រូវ ង៉ូវហ៊ួង |
| ៥៥ | រោងម៉ាស៊ីនកិនស្រូវ លី ស៊ាង ឈាន |
| ៥៦ | រោងម៉ាស៊ីនកិនស្រូវ ហួង ឡេង |

រហូតមកដល់ពេលនេះក្រុមហ៊ុនអ្នកនាំចេញ និង រោងម៉ាស៊ីនកិនស្រូវចំនួន **៥៦** ហើយដែលបានចុះហត្ថលេខាលើ ក្រមសីលធម៌របស់ ស.អ.ក។



# ព័ត៌មានអំពីបច្ចុប្បន្នភាព និងបញ្ហាប្រឈមសំខាន់នៃរោងម៉ាស៊ីនកិនស្រូវនៅកម្ពុជា

## "រោងម៉ាស៊ីនកិនស្រូវ៖ បញ្ហាប្រឈមសំខាន់ៗចំនួន ៧តម្រូវឲ្យមានដំណោះស្រាយជាបន្ទាន់"

ដើម្បីស្វែងយល់អំពីបញ្ហាប្រឈមសំខាន់ៗរបស់រោងម៉ាស៊ីនកិនស្រូវនាពេលបច្ចុប្បន្ន ក្រុមបុគ្គលិកសហព័ន្ធស្រូវអង្ករកម្ពុជា បានចុះជួបសំណេះសំណាលជាមួយសមាជិករោងម៉ាស៊ីនកិនស្រូវនៅតាមបណ្តាខេត្តមួយចំនួនរួមមាន ខេត្តព្រៃវែង ត្បូងឃ្មុំ កំពង់ចាម ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងកំពង់ធំ។ ជាលទ្ធផល សមាជិករោងម៉ាស៊ីនកិនស្រូវជាច្រើនបានលើកឡើងនូវបញ្ហាប្រឈម ប្រហាក់ប្រហែលគ្នាមួយចំនួន ដែលពួកគាត់បញ្ជាក់ថា ជាបញ្ហាប្រឈមសំខាន់ និងតម្រូវឲ្យមានដំណោះស្រាយជាបន្ទាន់ ដើម្បីឲ្យពួកគាត់អាចបន្តអាជីវកម្មទៅមុខទៀតបាន។ បញ្ហាប្រឈមសំខាន់ៗទាំងនោះរួមមាន៖

**១. បញ្ហាទីផ្សារ៖** ក្រៅពីភាពមិនសូវច្បាស់លាស់នៃទីផ្សារនាំចេញ ការបាត់បង់ ឬរួមតូចរបស់ទីផ្សារក្នុងស្រុកគឺជាបញ្ហាប្រឈមសំខាន់មួយផងដែរ ដែលពួកគាត់បានលើកឡើងថា ការកិនអង្ករលក់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុកមានការលំបាកពីមួយឆ្នាំទៅមួយឆ្នាំ ពិសេសការប្រកួតប្រជែងតម្លៃ និងការក្លែងបន្លំគុណភាព និងប្រភពអង្ករ។

**២. ការហូរចូលនូវអង្ករវៀតណាម៖** ទីផ្សារក្នុងស្រុកមួយភាគធំត្រូវបានបាត់បង់តាមរយៈការហូរចូលនូវអង្ករវៀតណាម ដែលមិនបានបង់ពន្ធគ្រប់ចំនួនត្រឹមត្រូវ និងដែលធ្វើឡើងដោយក្រុមអាជីវករខិលខូចមួយចំនួន។ ការក្លែងបន្លំគុណភាពដោយយកអង្ករនាំចូលពីវៀតណាម លាយជាមួយអង្ករខ្មែរហើយប្រើប្រាស់ឈ្មោះជាអង្ករខ្មែរ និងលក់ក្នុងតម្លៃថោកបាននិងកំពុងធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គុណភាព និងម៉ាកយីហោអង្ករខ្មែរ និងធ្វើឲ្យរោងម៉ាស៊ីនមួយចំនួនធំបិទទ្វារ មិនអាចដំណើរការអាជីវកម្មទៅមុខទៀតបាន។

**៣. ភ្លើងអគ្គិសនី៖** តម្លៃអគ្គិសនីនៅមានតម្លៃខ្ពស់ និងខុសគ្នាពីតំបន់មួយទៅតំបន់មួយ ដោយកន្លែងខ្លះមានតម្លៃរហូតដល់ជាង ១000រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង។ ក្រៅពីនេះ ការដាច់ភ្លើងញឹកញាប់ជាប្រចាំថ្ងៃក៏ជាបញ្ហាប្រឈមដ៏ធំមួយទៀត ដែលធ្វើរោងម៉ាស៊ីនពិបាកក្នុងការដំណើរការអាជីវកម្មរបស់ពួកគាត់។

**៤. ខ្វះទុនទិញស្រូវ៖** រោងម៉ាស៊ីនភាគច្រើនបានត្អូញត្អែរអំពីការខ្វះទុនបង្វិលក្នុងការប្រមូលទិញស្រូវស្តុកទុកសម្រាប់កិន ដែលជាហេតុធ្វើឲ្យស្រូវរបស់ប្រជាកសិករខ្មែរមួយភាគធំហូរចេញទៅប្រទេសជិតខាង ជាពិសេសប្រទេសវៀតណាម និងមិនអាចមានស្រូវគ្រប់គ្រាន់សម្រាប់ដំណើរការកិនរយៈពេលពេញមួយឆ្នាំបាន។

**៥. ការប្រាក់ថ្លៃ៖** អត្រាការប្រាក់នៅតាមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារពាណិជ្ជទាំងអស់នៅមានកម្រិតខ្ពស់ និងពិបាកទទួលបានប្រាក់កម្ចី។

**៦. ពន្ធដារ៖** ការបង់ពន្ធតាមរបបម៉ៅការនៅតែមានភាពស្មុគស្មាញនៅឡើយ ដោយមន្ត្រីពន្ធដារមួយចំនួនធំហាក់មិនមានភាពយោគយល់ដល់រោងម៉ាស៊ីនកិនស្រូវ។ លើសពីនេះ សមាជិករោងម៉ាស៊ីនកិនស្រូវបានស្នើសុំឲ្យមានការអនុគ្រោះនូវពន្ធអាករលើតម្លៃបន្ថែម VAT ១0% សម្រាប់រោងម៉ាស៊ីនកិនស្រូវ។

**៧. ការធ្លាក់ចុះផលិតផលស្រូវ៖** ការធ្លាក់ចុះនូវផលិតផលស្រូវរបស់ប្រជាកសិករ ដែលបណ្តាលមកពីការទុកដីទំនេរចោល និងការចំណាកស្រុករបស់កូនចៅរបស់កសិករ ក៏ជាក្តីកង្វល់មួយដ៏ធំរបស់រោងម៉ាស៊ីនផងដែរ។ ការខ្វះខាតនូវកំលាំងពលកម្មក្នុងវិស័យកសិកម្មត្រូវបានប្រជាកសិករត្អូញត្អែរ ខណៈដែលការខ្វះខាតប្រភពទឹក និងភាពមិនសូវចំណេញ ឬខាត ក្នុងការប្រកបរបរធ្វើស្រែត្រូវបានលើកឡើងផងដែរ។



# សម្រង់អត្ថបទព័ត៌មានសំខាន់ៗដែលបានចុះផ្សាយនៅក្នុងសារព័ត៌មានក្នុងស្រុក ពីខែតុលា ដល់ ខែធ្នូ ឆ្នាំ ២០១៥

## ក្រសួងពាណិជ្ជកម្មតម្រូវឲ្យក្រុមហ៊ុនជាង៤ម៉ឺនធ្វើការចុះបញ្ជីឡើងវិញ

ភ្នំពេញៈ ក្រសួងពាណិជ្ជកម្មបានស្នើឲ្យក្រុមហ៊ុនទាំងអស់ ដែលបានចុះបញ្ជីពាណិជ្ជកម្មរួចត្រូវធ្វើការចុះឈ្មោះក្រុមហ៊ុនរបស់ខ្លួនសាជាថ្មីឡើងវិញដោយប្រើប្រាស់ប្រព័ន្ធចុះបញ្ជីតាមអនឡាញ (e-Commerce) ចាប់ពីពេលនេះ រហូតដល់ថ្ងៃទី៣១ ខែមីនាឆ្នាំ២០១៦។
បើតាមការឲ្យដឹងរបស់ ឯ.ឧ ទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មគឺមានចំនួន៤២.០០០ក្រុមហ៊ុនតម្រូវឲ្យចុះបញ្ជីពាណិជ្ជកម្មឡើងវិញទាំងអស់ ដោយមិនគិតកម្រៃ។
ការប្រាប់ឲ្យដឹងនេះ បានធ្វើឡើងកាលពីថ្ងៃចន្ទ ក្នុងសន្និសីទសារព័ត៌មាន បន្ទាប់ពីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអនឡាញ និងការបង្ហាញពីទម្រង់នៃការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអនឡាញថ្មី ដែលបានធ្វើឡើងដោយក្រសួងពាណិជ្ជកម្ម ក្រោមគម្រោងជំនួយបច្ចេកទេសពីធនាគារពិភពលោក។ [---]

## ការនាំចេញអង្ករមិនសម្រេចតាមផែនការដោយសារកត្តា២យ៉ាង

សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានថ្លែងថា កម្ពុជាបានបរាជ័យនៅក្នុងការនាំចេញអង្ករឲ្យបាន ១លានតោន នៅក្នុងឆ្នាំ២០១៥នេះ ដោយសារតែកត្តា ២យ៉ាង
ក្នុងនោះមានកត្តាអត្តនោម័ត និង កត្តាសត្យានុម័ត។
តែទោះជាយ៉ាងណា សម្តេចនៅតែប្តេជ្ញា និងរក្សាជំហរនាំចេញអង្ករ ១លានតោន ឲ្យបានជោគជ័យ ព្រមទាំងជម្រុញឲ្យអ្នកពាក់ព័ន្ធខិតខំបន្ថែមទៀត ដើម្បីសម្រេចមហិច្ឆតាមួយនេះ។
កត្តាអត្តនោម័ត ត្រូវបានសម្តេចពន្យល់ថា បណ្តាលមកពីការខ្វះខាតថវិកាសម្រាប់ទិញអង្ករពីប្រជាពលរដ្ឋ ផលិតភាព និងការហូរចេញ ស្រូវទៅប្រទេសជិតខាង។ ចំណែកកត្តាសត្យានុម័ត ត្រូវបានសម្តេចពន្យល់ថា បណ្តាលមកពីវិបត្តិនៅក្នុងតំបន់ និងពិភពលោក គូប្រកួតប្រជែងច្រើន ហើយប្រទេសនានានៅតំបន់អាស៊ានបានផលិតស្រូវដូចៗគ្នាដើម្បីនាំចេញ។ [---]

## សម្តេចតេជោ ហ៊ុន សែនៈ ខ្ញុំបានដឹងទាំងអស់រាល់ការត្អូញត្អែររបស់កសិករពីស្រូវថោក

លោកនាយករដ្ឋមន្ត្រីប្រកាសថាលោក បានដឹងទាំងអស់រាល់ការត្អូញត្អែររបស់ប្រជាកសិករអំពីបញ្ហាតម្លៃស្រូវថោកពេកដែលធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់កសិករហើយលោកបញ្ជាឲ្យស្ថាប័នពាក់ព័ន្ធដោះស្រាយបញ្ហានេះ។
នៅក្នុងពិធីផ្សព្វផ្សាយរបាយការណ៍លទ្ធផលចុងក្រោយនៃការធ្វើជំរឿនលើវិស័យកសិកម្មនៅឆ្នាំ២០១៣កាលពីម្សិលមិញ លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ថ្លែងថាបើទោះជាលោកជាប់រវល់ធ្វើកិច្ចការផ្សេងក៏ដោយតែនៅតែទទួលបានព័ត៌មានពីការត្អូញត្អែររបស់កសិករពីបញ្ហាស្រូវថោក ៖ កសិករត្អូញណាស់ ហើយខ្ញុំសូមប្រកាសនៅទីនេះថា រាល់ការត្អូញត្អែររបស់កសិករខ្ញុំបានស្តាប់ឮ ប៉ុន្តែខ្ញុំគ្រាន់តែសុំបកស្រាយនៅទីនេះ ខ្ញុំបង្ហោះតាមហ្វេសបុករួចហើយខ្ញុំតាមមើលCommentទាំងអស់ តាមលទ្ធភាព និងពេលវេលាដែលខ្ញុំអាចមើលបាន។ ទោះបីខ្ញុំនិយាយរឿងទាត់បាល់ក៏Commentក្នុងណឹងថា សម្តេចសូមជួយមើលតម្លៃស្រូវផងថោកណាស់ ចឹងទេខ្ញុំសូមប្រកាសថា ខ្ញុំបានឮសំឡេងតាមការអំពាវនាវផ្សេងៗ តាមទូរទស្សន៍ តាមការជួបផ្ទាល់ រហូតដល់តាមហ្វេសបុកខ្ញុំបានដឹង។ [---]

## សម្តេចតេជោ ហ៊ុន សែន អនុញ្ញាតឱ្យពលរដ្ឋដែលខ្វះទឹកប្រើប្រាស់រាយការណ៍តាម Facebook ករណីពិបាកទាក់ទងអាជ្ញាធរ

(ភ្នំពេញ)៖ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានអនុញ្ញាតឱ្យប្រជាពលរដ្ឋគ្រប់គ្នា រាយការណ៍ដោយផ្ទាល់នៅលើទំព័រ Facebook របស់សម្តេច ក្នុងករណីលំបាកទាក់ទងសុំជំនួយពីអាជ្ញាធរ និងសមត្ថកិច្ច នៅពេលជួបប្រទះនឹងបញ្ហាខ្វះទឹក។
សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាស នៅលើទំព័រ Facebook សម្តេចនៅព្រឹកថ្ងៃអាទិត្យនេះថា «គ្រោះរាំងស្ងួត និងបញ្ហាកង្វះខាតទឹកប្រើប្រាស់ កំពុងបន្តគំរាមកំហែងដល់វិស័យកសិកម្មនៅក្នុងប្រទេសយើង។ ដូច្នេះសូមអាជ្ញាធរមានសមត្ថកិច្ច និងក្រសួងពាក់ព័ន្ធ បន្តជួយប្រជាពលរដ្ឋឲ្យ បានទាន់សភាពការណ៍ ដើម្បីកុំអោយខូចខាតផលដំណាំ ដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់បងប្អូនកសិករ»។
សម្តេចតេជោ **ហ៊ុន សែន** បញ្ជាក់បន្ថែមថា «ប្រសិនបើមានការលំបាកក្នុងការទំនាក់ទំនងទៅកាន់អាជ្ញាធរមានសមត្ថកិច្ច សូមប្រជាពលរដ្ឋផ្តល់ដំណឹងមកផ្ទាល់ តាមគេហទំព័រសម្តេចតេជោ ដោយភ្ជាប់ឈ្មោះ លេខទូរស័ព្ទទំនាក់ទំនាក់ទំង និងរូបភាពជាក់ស្តែងនៃទីតាំងនីមួយៗ និងចំនួនគ្រួសារដែលកំពុងរងគ្រោះ ប្រសិនបើអាចធ្វើបាន»៕ [---]

## ADBផ្តល់កម្ចី និងជំនួយ៦៤លានដុល្លារ កែលម្អប្រព័ន្ធធារាសាស្ត្រ និងទប់ស្កាត់ជម្ងឺឆ្លង

ធនាគារអភិវឌ្ឍន៍អាស៊ី ADB បានសម្រេចផ្តល់កម្ចី និងជំនួយឥតសំណង សរុប៦៤លានដុល្លារសម្រាប់គម្រោងចំនួន ២នៅកម្ពុជា។ ទី១. គម្រោងកែលំអប្រព័ន្ធធារាសាស្ត្រ ដែលជាកម្ចីមានទឹកប្រាក់៦០លានដុល្លារ និងទី២. ប្រព័ន្ធទប់ស្កាត់ និងតាមដានជំងឺគ្រុនចាញ់ ដែលជាជំនួយក្នុងទឹកប្រាក់ ៤ លានដុល្លារ ទឹកប្រាក់កម្ចី និងជំនួយនេះ ត្រូវបានចុះហត្ថលេខានៅថ្ងៃទី១០ខែវិច្ឆិកា ក្រោមអធិបតីភាព ឯ.ឧ បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោក **ជេន ហាសេន**(Jan Hansen) មន្ត្រីតំណាងADBប្រចាំកម្ពុជា។ [---]

## រាជរដ្ឋាភិបាលនឹងបោះបង់ចោលរបប បង់ពន្ធម៉ៅការ

ភ្នំពេញៈ ក្នុងការផ្លាស់ប្តូរដ៏សំខាន់សម្រាប់ប្រព័ន្ធពន្ធដាររបស់កម្ពុជា រដ្ឋាភិបាលនឹងលុបចោលរបបពន្ធម៉ៅការដែលត្រូវបានគ្រប់គ្រងតិចតួច និងដាក់បញ្ចូលក្រុមហ៊ុនអាជីវកម្មទាំងអស់នៅក្នុងកម្ពុជាឲ្យស្ថិត ក្រោមរបបពន្ធពិតផ្លូវការ។ នេះបើតាមសេចក្តីព្រាងច្បាប់ឆ្នាំ២០១៦ សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ។

# វេទិកាស្រូវអង្ករកម្ពុជាលើកទី ៥

# 5th Cambodia Rice Forum

***January 24 - 25 - 26, 2016 at Sokha Phnom Penh Hotel & Residence***





Organizer:

CAMBODIA RICE FEDERATION

Co-Organizer

FASMEC

Official Supporters

CDC

IFC International Finance Corporation

USAID

Contact Us: +855 (0)12 343 451 / +855 (0) 81 261 027 / info.crf2015@crf.org.kh

Cambodia Rice forum 5th

## សូមស្វាគមន៍ និងអញ្ជើញចូលរួម

តុលា - ធ្នូ ៤

# ពិធីបុណ្យស្រូវអង្ករកម្ពុជា ២០១៦



*ថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៦ នៅសណ្ឋាគារសុខាភ្នំពេញ*
*ចាប់ពីម៉ោង ១ ដល់ម៉ោង ៥ រសៀល (ចូលរួមដោយសេរី)*



# វេទិកាស្រូវអង្ករកម្ពុជាលើកទី ៥

*ចំពោះថ្ងៃទី ២៥ ដល់ ២៦ ខែមករា ឆ្នាំ ២០១៦*
*(សម្រាប់តែអ្នកត្រូវបានអញ្ជើញ និងចុះឈ្មោះ)*

## អត្ថប្រយោជន៍ដែលអ្នកចូលរួមនឹងទទួលបាន

_ ឱកាសជួបជាមួយអ្នកជំនាញការ និងអ្នករកស៊ីក្នុងវិស័យស្រូវអង្ករជាតិ និងអន្តរជាតិ
_ ចូលរួមទស្សនាកម្មវិធីប្រកួតស្រូវអង្ករប្រចាំប្រទេសកម្ពុជា
_ ទស្សនាការសម្តែងសិល្ប: និងរបាំជាច្រើនប្រភេទទាក់ទងនឹងវិស័យស្រូវអង្ករ
_ ចូលរួមប្រកួតមុខម្ហូប ដែលផលិតចេញពីអង្ករ ដោយសមាគមចុងភៅ
_ ភ្លក់មុខម្ហូបខ្មែរជាច្រើនមុខដោយសេរី និងដោយឥតគិតថ្លៃ
_ ចូលរួមទស្សនាការតាំងបង្ហាញអំពីខ្សែសង្វាក់ផលិតកម្មស្រូវអង្ករទាំងមូល
_ ឱកាសទទួលបានចំណេះនឹងបទពិសោធន៍ថ្មីៗក្នុងវិស័យស្រូវអង្ករនៅកម្ពុជា

| Organizer | Co-Organizer |
|---|---|
| CAMBODIA RICE FEDERATION | FASMEC |

Offical Supporters

CDC · IFC International Finance Corporation · USAID

www.crf.org.kh / www.facebook.com/cambodiaricefederation

Cambodia Rice forum 5th — វេទិកាស្រូវអង្ករកម្ពុជា លើកទី ៥

January 24 - 25 - 26, 2016 at Sokha Phnom Penh Hotel & Residence



# ប៊ឺឡឺ (Bühler) នៅក្នុងវិស័យស្រូវអង្ករ

## ជាដៃគូរបស់អ្នកជំនួញស្រូវអង្ករ ហើយក៏ជាផ្នែកមួយនៃឧស្សាហកម្មកែច្នៃអង្ករផងដែរ

ដោយឆ្លងកាត់បទពិសោធន៍ជាង ១៥០ ឆ្នាំ ជាមួយនឹងការរៀបចំប្លង់ ការតម្លើងគម្រោងកិន និងការកែច្នៃអង្ករដែលទទួលបានជោគជ័យជាច្រើន ប៊ឺឡឺ (Bühler) បាននាំមកនូវផលិតផលដែលមានគុណភាពខ្ពស់ ទំនើបទាន់សម័យ បង្កើនប្រាក់ចំណេញ និងកាត់បន្ថយថ្លៃដើមទៅលើដំណើរការម៉ាស៊ីន។




លក្ខណៈម៉ាស៊ីនកិនស្រូវរបស់ប៊ឺឡឺ (Bühler) - ទំនើបទាន់សម័យ ស្អាត រោងចក្រកែច្នៃអង្ករទាំងមូលដើរដោយប្រព័ន្ធស្វ័យប្រវត្តិដែលភ្ជាប់ជាមួយនឹងបច្ចេកវិទ្យារូបភាពទីតាំងធ្វើការរបស់ម៉ាស៊ីន ។

1. ផ្នែកប្រព័ន្ធបឺតខ្យល់ និងបញ្ជូន
2. ផ្នែកប្រព័ន្ធបញ្ជាស្វ័យប្រវត្តិ
3. ផ្នែកសម្អាតស្រូវ (កញ្ច្រែងសម្អាត និងម៉ាស៊ីនរែងគ្រួស) (មើលមិនឃើញ)
4. ម៉ាស៊ីនបកសម្បកស្រូវ (ណូដា)
5. ម៉ាស៊ីនញែកស្រូវ (កញ្ច្រែងងោក)
6. ផ្នែកត្បាល់ស
7. ម៉ាស៊ីនរែងកញ្ចុំអង្ករ
8. ម៉ាស៊ីនប៉ូលា
9. ម៉ាស៊ីនរើសពណ៌អង្ករ
10. តៅស្តុក
11. ជញ្ជីងថ្លឹង (មើលមិនឃើញ)
12. ម៉ាស៊ីនវេចខ្ចប់ (មើលមិនឃើញ)

**Turnkey capabilities:**
ការគ្រប់គ្រង និងរក្សាទុកគ្រាប់ធញ្ញជាតិ ការកែច្នៃកាកសំណល់ពីអង្ករ វិស្វកម្ម និងការគ្រប់គ្រងគម្រោង ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ព្រមទាំងការជួយទំនុកបម្រុងផ្នែកបច្ចេកវិទ្យាដែលទទួលបាននូវការគាំទ្រពីបណ្ដាប្រទេសជាង ១៤០ ទូទាំងពិភពលោក ។

### ការរក្សាទុក (**Storage**):



Flat Storage

- សម្រាប់ផលិតផលលំហូរសេរី និងលំហូរមិនសេរី
- ការបញ្ចូល និងបញ្ចេញដោយប្រព័ន្ធមេកានិច
- បង្កើនចំណុះផ្ទុក
- ប្រើថាមពលភ្លើងតិច

### ម៉ាស៊ីនសម្អាត (**Cleaning**):



Schmidt-Seeger TAS™

- ម៉ាស៊ីនសម្អាតមានបន្ទប់ធំទូលាយទាំងការសម្អាត ការបែងចែកចំណាត់ខ្នាត និងប្រព័ន្ធបឺតខ្យល់
- ម៉ាស៊ីនដំណើរការរលូនកាត់បន្ថយការបាក់គ្រាប់ស្រូវ

### ម៉ាស៊ីនរើសពណ៌ (**Optical Sorting**):



SORTEX S UltraVision™

- ម៉ាស៊ីនមានសមត្ថភាពខ្ពស់មានរហូតដល់ខ្នាត 6 ទ
- បង្ហាញពីគុណភាពបច្ចេកវិទ្យាចុងក្រោយរបស់ម៉ាស៊ីនរើសពណ៌អង្ករ ដែលជាកម្មសិទ្ធថ្មីទាំងអស់របស់ប៊ឺឡឺ (Bühler)
- ងាយស្រួលក្នុងការប្រើ និងជួសជុល ជាមួយកម្មវិធី SORTEX ProSort™ Software

Buhler (Cambodia) Ltd.
#86, Street 388, Kim Hab Building (2nd Floor), Sangkat Toul Svay Prey II,
Khan Chamkarmorn, Phnom Penh, Cambodia
T: +855 23 985 282
office.cambodia@buhlergroup.com, www.buhlergroup.com/rice

BÜHLER




# CONNECT

## WITH THE BANK THAT'S BEEN

# SUPPORTING CUSTOMERS

## FOR 180 YEARS

As a customer of ANZ's super regional network, you can now capitalise on the stability and expertise of one of the safest banks in Asia Pacific. Because of our commitment to the highest banking standards, we've been consistently recognised for our long-term creditworthiness and strength:

- Voted Best Trade Finance Bank in Cambodia by Global Finance Magazine[1]
- Cambodia's Bank of the Year[2]
- Top 4 Corporate Bank in Asia by Greenwich Associates[3]
- One of the world's top 25 banks by market capitalisation[4]
- Ranked 19 on Global Finance Magazine's World's 50 Safest Banks[5]
- Over 10 million customers around the world

023 999 000

With a network that spans across 29 markets in Asia Pacific, you can now have access to more financial expertise that connects you to the right products, the right people and the right opportunities. And our significant financial assets ensure that we are well-positioned to support your individual or business lending requirements so as to reach your goals.

With ANZ Royal, you'll have a reliable partner who can take care of all your financial needs, wherever you need it.

1 Global Finance Magazine 2015 2 The Banker magazine, Bank of the Year Awards 2006, 2011 and 2013
3 Source: Greenwich Associates Asian Large Corporate Banking Survey 2013 4 Based on market capitalisation
5 As at September 2014

anzroyal.com

ANZ Royal
YOUR WORLD, YOUR WAY

នីកូលីន អ៊ិនវេសមេន ខូ., អិលធីឌី

NIKOLINE INVESTMENT CO., LTD

## NIKOLINE RICE MILL

- Established in 2010 and continue to provide only the best quality rice from Cambodia.

- Cap: 50,000Mt/year

- Products:

  - Jasmine Rice
  - Fragrant Rice (Sean Kra Ob)
  - Long Grain White Rice
  - Brown Rice



- Packaging:
  + 1-10 kg (vacuumed & Non vacuumed)
  + 10-50Kg PP or PP+PE Bag
  + Jumbo & Liner Bag





Contact: **Mr NORNG VEASNA, Director of Sales,** Mobile: (855) 12 400 112 (available on what's app & LINE) Email: rice.veasnanorng@gmail.com
**Mr. HONG NIKOLINE** , Mobile: ( +855) 77 777 708 Email: nikoline@nklrice.com
**Mr Vinh Cheang**, Mobile: (+855)12 933 737 Email: v.cheang7ricemill@gmail.com Visit us @ www.nikoline.com.kh

**P. PENH Office**:#17, Street 334, Sangkat Beoung Kengkang 1, Khan Chamkamorn, Phnom Penh, CAMBODIA
**Mill**: Veal Kangdeang Village, Chup Commune, Tboung Khmum District, Tboung Khmum Province, CAMBODIA

ផ្សព្វផ្សាយ និងបោះពុម្ពដោយ៖

CAMBODIA RICE FEDERATION

គាំទ្រដោយ៖

IFC International Finance Corporation World Bank Group

afd AGENCE FRANÇAISE DE DÉVELOPPEMENT

CDC

អគារពាណិជ្ជកម្មសូម៉ា ជាន់ទី ៧ អាគារលេខ ២C ផ្លូវលេខ ១២០ សង្កាត់ ផ្សារថ្មី ॥ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ៖ www.crf.org.kh / Facebook Page: https://www.facebook.com/cambodiaricefederation
សារអេឡិចត្រូនិក៖ info@crf.org.kh ទូរស័ព្ទ៖ +៨៥៥ (0) ២៣ ៥៥៩ ៨៩៩៩